




# សួនដំណាំជាលក្ខណៈគ្រួសារ

## សៀវភៅជាជំនួយដល់អ្នកផ្សព្វផ្សាយ



**ណារីអន្តរជាតិដើម្បីអភិវឌ្ឍន៍**

**ឧបត្ថម្ភថវិកាដោយប្រជាជនអូស្ត្រាលី**

**International Women's Development Agency (IWDA), 1999**
**Funded by People of Australia**

ស្ទូនដំណាំជាលក្ខណៈគ្រួសារ

សៀវភៅជាជំនួយដល់អ្នកផ្សព្វផ្សាយ


អត្ថបទដោយ : អាឌិនឌុ ឆាតធើជី និង យ៉ង់ សាំងកុមារ

Text by: Ardhendu. S. Chatterjee and Yang Saing Koma

បកប្រែដោយ : ប៉ាន់ ពុទ្ធារី និង ពាន សុខា

Translation: Pan Putheary and Pean Sokha

រូបភាពដោយ : អាឌិនឌុ ឆាតធើជី និង សាតូកូ

Illustrations: Ardhendu. S. Chatterjee and Satoko

ក្របខាងក្រៅ : ពាន សុខា និង មាស និមល

Cover: Pean Sokha and Meas Nimol



បោះពុម្ពដោយ : មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
សំរាប់នារីអន្តរជាតិដើម្បីអភិវឌ្ឍន៍ តាមរយៈថវិកា"ប្រជាជនអូស្ត្រាលី"

Published by: Centre d'Etude et de Développement Agricole Cambodgien (CEDAC)
for International Women's Development Agency
Funded by People of Australia

# សួនដំណាំជាលក្ខណៈគ្រួសារ

## សៀវភៅជាជំនួយដល់អ្នកផ្សព្វផ្សាយ

នារីអន្តរជាតិដើម្បីអភិវឌ្ឍន៍

ឧបត្ថម្ភថវិកាដោយប្រជាជនអូស្ត្រាលី

**International Women's Development Agency (IWDA), 1999**
**Funded by People of Australia**

# មាតិកាអត្ថបទ

ទំព័រ


អារម្ភកថា

១. តួនាទីរបស់អ្នកផ្សព្វផ្សាយសួនដំណាំ ១

២. វិធីក្នុងការបង្កើនគុណភាពសួនតាមគ្រួសារ ៣

៣. ដីល្អ (វិធីក្នុងការសំគាល់ដី) ៨

៤. ការថែរក្សា និង កែលំអដីជាតិដី ១៣

៥. ដំណាំ និង ទឹក ២៥

៦. ការជ្រើសរើសដំណាំ ៣៦

៧. ការការពារដំណាំ ៥៦

៨. ការចិញ្ចឹមជីវិត និង ចំណីអាហាររបស់មនុស្ស ៥៨

ឧបសម្ព័ន្ធទី ១ ៦៣

ឧបសម្ព័ន្ធទី ២ ៦៥

ឧបសម្ព័ន្ធទី ៣ ៦៦

ទំព័រពន្យល់ពាក្យបច្ចេកទេស ៦៨

– លិបិក្រម ៧៣

# បញ្ជីរូបភាពសំរាប់សៀវភៅបង្រៀនកសិកម្មចំរុះ


ទំព័រ

- រូបភាពទី ១ : ប្រភេទដំណាំបន្លែដែលដាំនៅក្នុងរដូវផ្សេងៗគ្នា ៥
- រូបភាពទី ២ : សួនដំណាំបង្ហាញអំពីដំណាំមួយចំនួន និងដើមឈើ ៥
- រូបភាពទី ៣ : រូបភាពសួនទាំងមូល ៦
- រូបភាពទី ៤ : ដីស្រទាប់លើ និង ដីស្រទាប់ក្រោម ៩
- រូបភាពទី ៥ : ការហូរសឹកដីស្រទាប់លើទៅតាមល័ក្ខខ័ណ្ឌផ្សេងៗ ១១
- រូបភាពទី ៦ : សញ្ញាសំគាល់នៃសំណឹកដីស្រទាប់លើ ១២
- រូបភាពទី ៧ : មីក្រូសរីរាង្គក្នុងដី ១៤
- រូបភាពទី ៨ : របៀបតេស្តដីមើលរាយណភាព និង សារធាតុសរីរាង្គរបស់ដី ១៥
- រូបភាពទី ៩ : ការរៀបចំធ្វើជីកំប៉ុស្តរាវ ១៧
- រូបភាពទី ១០ : ការធ្វើកំប៉ុស្តគោក (របៀបរៀបជាស្រទាប់ផ្សេងៗ) ១៨
- រូបភាពទី ១១ : ជីស្លឹកឈើស្រស់ ១៩
- រូបភាពទី ១២ : ដំណាំចំរុះ ១៩
- រូបភាពទី ១៣ : របៀបកាប់មែកយកស្លឹកធ្វើជីស្រស់ ២០
- រូបភាពទី ១៤ : ដំណាំបណ្តក់ / បង្វិល ២១
- រូបភាពទី ១៥ : របៀបដាំគ្របដី ២២
- រូបភាពទី ១៦ : របៀបកែលំអជីជាតិដីតាមរយៈការធ្វើរងជ្រៅ ហើយនិងគ្របរង ២២
- រូបភាពទី ១៧ : សួនរង្វង់ ២៣
- រូបភាពទី ១៨ : ការដាំរុក្ខជាតិជាជួររបាំងនៅលើដីដែលមានចំណោត ២៤
- រូបភាពទី ១៩ : តំរូវការទឹកមធ្យមរបស់ដំណាំបន្លែ តាមដំណាក់កាលលូតលាស់របស់ដំណាំ ២៦
- រូបភាពទី ២០ : សមត្ថភាពរបស់ដីក្នុងការរក្សាទឹកទុកក្នុងស្រទាប់លើ ២៨
- រូបភាពទី ២១ : ការតេស្តមើលលក្ខណៈរបស់ដីក្នុងការបង្ហូរទឹកចុះក្រោម (តើដីជាំទឹកខ្លាំង ឬមិនជាំទឹក) ២៩
- រូបភាពទី ២២ : ការគ្របដីដោយស្លឹករុក្ខជាតិស្ងួត ឬស្មៅ ចំបើង ឬថ្ម អាចបន្ថយការបាត់បង់នូវរំហួតបាន ៣០
- រូបភាពទី ២៣ : រុក្ខជាតិដែលអាចធន់ទ្រាំនឹងភាពរាំងស្ងួត (ឧទាហរណ៍ខ្លះៗ) ៣០
- រូបភាពទី ២៤ : ដំណាំច្រើនជាន់ ៣១
- រូបភាពទី ២៥ : សួនរង្វង់ដែលមានដំណាំចំរុះ ៣១

- រូបភាពទី ២៦ : ការប្រើប្រាស់ទឹកជាកាកសំណល់សំរាប់ស្រោចដំណាំ ៣២
- រូបភាពទី ២៧ : របៀបដាំក្នុងករណីខ្វះខាតទឹក ឬនៅរដូវប្រាំងដោយប្រើក្លប ឬដប ៣២
- រូបភាពទី ២៨ : រងដែលកប់ជ្រៅ ហើយបំពេញដោយសារធាតុសរីរាង្គ ៣៣
- រូបភាពទី ២៩ : សួនកង់ឡាន ៣៣
- រូបភាពទី ៣០ : របៀបដាំប្រើធ្នើរ ឬរងខ្ពស់ផុតពីដី ៣៤
- រូបភាពទី ៣១ : របៀបដាំនៅលើដីដែលជាំទឹក ឬលិចទឹក ៣៤
- រូបភាពទី ៣២ : ការជ្រើសរើសដំណាំទៅតាមជីជាតិដី ៣៧
- រូបភាពទី ៣៣ : ការជ្រើសរើសដំណាំទៅតាមតំរូវការជីជាតិពីដី ៣៨
- រូបភាពទី ៣៤ : ការជ្រើសរើសដំណាំទៅតាមភាពសម្របនឹងកំដៅ (សីតុណ្ហភាព) ៣៩
- រូបភាពទី ៣៥ : ប្រព័ន្ធរបស់ដំណាំ ៤០
- រូបភាពទី ៣៦ : ការបែងចែកដំណាំទៅតាមតំរូវការពន្លឺ ៤២
- រូបភាពទី ៣៧ : ការបែងចែកដំណាំទៅតាមរបៀបដាំបន្ត ៤៣
- រូបភាពទី ៣៨ : របៀបព្រោះ ដាំ និង ស្ទូង ៤៤
- រូបភាពទី ៣៩ : គោលការណ៍សំខាន់ក្នុងការជ្រើសរើសគ្រាប់ពូជ និងកូនដំណាំ ៤៧
- រូបភាពទី ៤០ : របៀបរក្សាទុកគ្រាប់ពូជ ៤៨
- រូបភាពទី ៤១ : ពពួកសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតខ្លះទៀតគ្មានប្រយោជន៍ (ចង្រៃ) នៅក្នុងសួនដំណាំ ៤៩
- រូបភាពទី ៤២ : គំនិតខ្លះសំរាប់អនុវត្តក្នុងការការពារដំណាំ ៥០
- រូបភាពទី ៤៣ : វិធានការផ្សេងៗដើម្បីធានាឲ្យកូនដំណាំ ឬពូជដំណាំដែលមានសុខភាពល្អ ៥២
- រូបភាពទី ៤៤ : ការការពារដំណាំក្នុងដំណាក់កាលលូតលាស់ ៥៣
- រូបភាពទី ៤៥ : ការបែងចែកដំណាំទៅតាមគ្រួសារ ៥៤
- រូបភាពទី ៤៥ : ការបែងចែកដំណាំទៅតាមគ្រួសារ ៥៥
- រូបភាពទី ៤៥ : ការបែងចែកដំណាំទៅតាមគ្រួសារ ៥៦
- រូបភាពទី ៤៦ : ការការពារដំណាំតាមរយៈការធ្វើរបង និងរបាំងការពារ ៥៧
- រូបភាពទី ៤៧ : ការបែងចែកដំណាំទៅតាមប្រភពសារធាតុចិញ្ចឹម ៥៩
- រូបភាពទី ៤៧ : ការបែងចែកដំណាំទៅតាមប្រភពសារធាតុចិញ្ចឹម ៦០
- រូបភាពទី ៤៨ : ឧទាហរណ៍ខ្លះៗ អំពីរបៀបកែច្នៃ និងចំអិន ៦១

# អារម្ភកថា

យើងរៀបចំសៀវភៅនេះឡើង ដើម្បីជាឯកសារជំនួយដល់លោក-អ្នកដែលកំពុងបំពេញការងារផ្សព្វផ្សាយស្ទូងដំណាំជាលក្ខណៈគ្រួសារ នៅប្រទេសកម្ពុជាយើង ។

ការផ្តើមគំនិតឲ្យមានជាសៀវភៅនេះឡើង គឺចេញមកពីបុគ្គលិករបស់អង្គការនារីអន្តរជាតិដើម្បីអភិវឌ្ឍន៍ (IWDA) ដែលជាអង្គការអូស្ត្រាលីមួយកំពុងបំពេញការងារនៅខេត្តបាត់ដំបង និងសៀមរាប ។ អង្គការនារីអន្តរជាតិ យល់ឃើញថា ដើម្បីពង្រឹង និងពង្រីកកម្មវិធីស្ទូងដំណាំជាលក្ខណៈគ្រួសារ ឲ្យមានប្រសិទ្ធិភាព លុះត្រាតែមានកសិករគំរូ ជាអ្នកចូលរួមចំណែកក្នុងការងារផ្សព្វផ្សាយ ។ ដូចនេះ គេគួរតែជ្រើសរើសកសិករគំរូមកបណ្តុះបណ្តាលបន្ថែម ដើម្បីពង្រឹងសមត្ថភាព ក៏ដូចជារៀបចំឲ្យមានឯកសារជាភាសាខ្មែរឲ្យបានច្រើន ដើម្បីជាជំនួយដល់ការងាររបស់គាត់ ។ ក្នុងបរិបទនេះ កូនសៀវភៅ *"ស្ទូងដំណាំជាលក្ខណៈគ្រួសារ"* ត្រូវបានចងក្រង ដើម្បីឆ្លើយតបទៅនឹងតំរូវការជាក់ស្តែង នៃការងារផ្សព្វផ្សាយរបស់នារីអន្តរជាតិដើម្បីអភិវឌ្ឍន៍ ក៏ដូចជាអង្គការផ្សេងៗទៀត ។

មានបុគ្គលជាច្រើនបានចូលរួមចំណែកក្នុងកិច្ចការនេះរៀបចំសៀវភៅនេះ ។ អ្នកសំខាន់ៗ មានដូចជា លោក អេឌិនឌុ ឆាតជីជី **(A. S. Chatterjee)** ដែលជាអ្នកចូលរួមក្នុងការសរសេរអត្ថបទ អ្នកស្រី ម៉ែន ឡាវី ដែលបានបកប្រែអត្ថបទ អ្នកស្រី សាតូកូ **(Satoko)** បានជួយក្នុងការគូររូបភាព អ្នកស្រី នូ សុគន្ធ និង អ្នកស្រី ញាន សារេខន ដែលជាអ្នកផ្តើមគំនិត និងជួយកែសំរួលអត្ថបទជាភាសាខ្មែរ ។ ទន្ទឹមនេះ យើងក៏សូមអរគុណដល់បុគ្គលិកនៃផ្នែកបោះពុម្ពនិងឯកសារ របស់មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) ជាពិសេស អ្នកស្រី ពាន សុខា អ្នកស្រី មាស និមល និង កញ្ញា ម៉ឺន ស្រីមុំ ដែលបានចំណាយពេលយ៉ាងច្រើនក្នុងការបោះពុម្ពផ្សាយ ។ យើងសូមថ្លែងអំណរគុណផងដែរដល់កសិករជាដៃគូរបស់អង្គការ អាយដា ដែលបានជួយផ្តល់យោបល់ល្អៗ សំរាប់ធ្វើយ៉ាងណាឲ្យសៀវភៅនេះមានលក្ខណៈងាយស្រួលសំរាប់អាន ។

សៀវភៅនេះអាចបោះពុម្ពផ្សាយបាន ក៏ដោយសារតែការជួយឧបត្ថម្ភថវិកាពីប្រជាជនអូស្ត្រាលី (People of Australia) ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនទាំងអស់ ។

ក្រុមអ្នកនិពន្ធសង្ឃឹមថា សៀវភៅនេះអាចជាជំនួយមួយដល់ការងាររបស់លោក-អ្នក ដែលជាអ្នកផ្សព្វផ្សាយ ហើយយើងសូមស្វាគមន៍ និងថ្លែងអំណរគុណទុកជាមុនចំពោះយោបល់កែលំអរផ្សេងៗ សំរាប់ការបោះពុម្ពលើកក្រោយ ។

ភ្នំពេញ ខែមករា ឆ្នាំ ១៩៩៩

យ៉ង សាំងកុមារ

**Yang Saing Koma**

## ១_ តួនាទីរបស់អ្នកផ្សព្វផ្សាយសួនដំណាំ

**គោលបំណង :**

*បន្ទាប់ពីអានជំពូកនេះចប់ អ្នកអាចយល់បានថា :*

- តើអ្នកផ្សព្វផ្សាយសួនដំណាំ មានភារកិច្ច និងតួនាទីសំខាន់ៗអ្វីខ្លះ ?
- តើអ្នកត្រូវបំពេញនូវលក្ខខ័ណ្ឌសំខាន់ៗអ្វីខ្លះ ដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសួនដំណាំម្នាក់ ?

អ្នកទាំងអស់គ្នា ជាអ្នកធ្វើការងារអភិវឌ្ឍន៍ប្រចាំភូមិ ។ អ្នកធ្វើការជាមួយប្រជាជនដើម្បីបង្កើនកំរិតជីវភាពរបស់ពួកគេតាមរយៈការផ្តល់សេវាកម្មផ្សេងៗ ដូចជាជួយរៀបចំគម្រោងការ ផ្គត់ផ្គង់សំភារៈសំរាប់ដំណើរការផលិតកម្ម និងឥណទាន ។ល។ អ្នកក៏អាចជួយអ្នកភូមិបង្កើតជាក្រុមសន្សំប្រាក់ បង្កើតឲ្យមានធនាគារស្រូវ ឬសហការជាមួយគ្នាដើម្បីសាងសង់ផ្លូវថ្នល់ ឬស្រះសហគមន៍ ។

ក្នុងតួនាទីអ្នកជាអ្នកផ្សព្វផ្សាយសួនដំណាំ អ្នកអាចជួយដល់អ្នកភូមិ ពិសេសស្ត្រីឲ្យរៀនសូត្រអំពីរបៀបកែលំអសួនដំណាំឲ្យក្លាយទៅជាសួនមួយដែលអាចផលិតបន្លែ ម្ទេសទេស និងឈើហូបផ្លែ ដែលសំបូរដោយសារធាតុចិញ្ចឹមជីវិតបានគ្រប់រដូវ តាមរយៈការប្រើប្រាស់កំលាំងពលកម្ម និងធនធានផ្ទាល់ខ្លួន (ឬធនធានដែលអាចផលិត និងបង្កើតបានឡើងវិញដោយកសិករ) ។ អ្នកអាចនឹងជួយផ្តល់ឲ្យពួកគេនូវគ្រាប់ពូជខ្លះ និងបង្រៀនពួកគេនូវបច្ចេកទេសមួយចំនួន ។

ក៏ប៉ុន្តែតួនាទីចំបងរបស់អ្នកមិនត្រឹមប៉ុណ្ណឹងទេ អ្នកគួរតែជួយអ្នកភូមិឲ្យគាត់ចេះរៀនសូត្រពីគ្នាទៅវិញទៅមក និង សាកល្បងនូវបច្ចេកទេសថ្មីៗ ដែលជាបទពិសោធន៍របស់កសិករនៅស្រុក ឬខេត្តផ្សេងៗ ដែលស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា ។ សួនល្អអាចធ្វើទៅបាន ដោយមិនចំណាយអស់ប្រាក់ច្រើន ត្រូវការទឹក និងកំលាំងពលកម្មតែបន្តិចបន្តួចប៉ុណ្ណោះ ។ ក៏ប៉ុន្តែ វាក៏អាស្រ័យទៅលើការមានគំរោង និងរៀបចំឲ្យបានល្អដែរ ។ ក្នុងការរៀបចំសួន យើងគួរធ្វើយ៉ាងណាប្រើអស់នូវធនធានដែលមានស្រាប់ ជ្រើសរើសពូជដំណាំឲ្យសមស្របទៅតាមដី និងអាកាសធាតុរបស់តំបន់ និងជៀសវាងក្នុងការប្រើជីគីមី និងថ្នាំសំលាប់សត្វល្អិត ។ អ្វីដែលអ្នកត្រូវប្រឹងប្រែងនោះ គឺបង្កើននូវកិច្ចសហការទៅវិញទៅមកជាមួយប្រជាជន និងជំរុញនូវការរៀនសូត្រតាមរយៈអនុវត្តផ្ទាល់មួយជំហានម្តងៗ ។

ដើម្បីបំពេញនូវតួនាទី និងភារកិច្ចដូចរៀបរាប់ខាងលើនេះបាន វាទាមទារឲ្យអ្នកផ្សព្វផ្សាយបំពេញនូវលក្ខខ័ណ្ឌសំខាន់ៗ ដូចខាងក្រោមនេះ

- អ្នកផ្សព្វផ្សាយត្រូវមានចំណេះដឹង និងបទពិសោធន៍ជាមូលដ្ឋាន ទាក់ទងទៅនឹងគំនិត ឬបច្ចេកទេសផ្សេងៗ សំរាប់កែលំអសួនដំណាំ

- អ្នកត្រូវមានជំនាញក្នុងការប្រមូលព័ត៌មាន វិភាគនូវបញ្ហាជាមួយម្ចាស់សួន ក៏ដូចជាជំនាញក្នុងការសម្របសម្រួល ឬដឹកនាំការប្រជុំពិភាក្សា ប្តូរនូវបទពិសោធន៍រវាងម្ចាស់សួន និង ម្ចាស់សួន

- អ្នកត្រូវមានទឹកចិត្តស្រឡាញ់សួនដំណាំ រីករាយនឹងធ្វើការជាមួយកសិករ រក្សានូវទំនាក់ទំនងល្អជាមួយគាត់

- អ្នកត្រូវមានទឹកចិត្តស្រឡាញ់រាប់អានកសិករស្មើភាពគ្នា មិននិយមបក្ខពួក ឬគ្រួសារនិយម

## ២_ វិធីក្នុងការបង្កើនគុណភាពសួនតាមគ្រួសារ

> **គោលបំណង :**
>
> *បន្ទាប់ពីអានជំពូកនេះចប់ អ្នកនឹងអាច :*
>
> - យល់បាននូវចំណុចណែនាំសំខាន់ៗឬយចំនួនសំរាប់ជួយឲ្យអ្នកអាចវាយតំលៃនូវស្ថានភាពនៃការធ្វើសួន នៅតាមភូមិដែលអ្នកកំពុងបំពើការងារ និងបញ្ហាដែលម្ចាស់សួនកំពុងជួបប្រទះ
> - ធ្វើការកំណត់នូវគុណភាព ឬលក្ខណៈចំបងរបស់សួនគ្រួសារដែលល្អ

ក្នុងការងារអភិវឌ្ឍន៍សួនដំណាំ ជំហានដំបូងដែលគេត្រូវអនុវត្តគឺកំណត់ឲ្យច្បាស់នូវបញ្ហា ទើបឈានទៅដល់ការរៀបចំនូវដំណោះស្រាយសមស្រប ។ យើងចាំបាច់ត្រូវសង្កេតមើលសួននៅតាមមូលដ្ឋាន និងកត់ត្រានូវដំណាំដែលប្រជាជនបានដាំ ទាំងដំណាំតាមរដូវ និង ដំណាំយូរអង្វែង ។ យើងក៏ត្រូវការពិភាគ ឬឆ្លើយនូវសំនួរសំខាន់ៗដូចខាងក្រោមនេះ ៖

- ✧ តើខែណាខ្លះដែលគេមិនអាចដាំដំណាំបានច្រើន ?
- ✧ តើផ្ទៃដីប៉ុន្មានដែលនៅទំនេរមិនបានប្រើប្រាស់ តើប្រជាជនអនុវត្តរបៀបដាំច្រើនជាន់ដែរឬទេ?
- ✧ តើប្រជាជនមានដាំបន្លែដែលអាចធន់ទ្រាំបាននឹងសត្វល្អិត ឬជំងឺដែរឬទេ ?
- ✧ តើគេអាចសន្សំពូជទុកបានដោយខ្លួនឯងឬទេ ?
- ✧ តើម្ចាស់សួនអាចការពារដំណាំមិនឲ្យសត្វស្លាប សត្វពាហនៈបំផ្លាញ បានប្រសិទ្ធិភាពឬទេ ? តើគេអនុវត្តនូវវិធីសាស្ត្រអ្វីខ្លះ ?
- ✧ តើជីជាតិដីរបស់សួនយ៉ាងណាដែរ ? ហើយកន្លងមកគេអនុវត្តយ៉ាងដូចម្តេចដែរដើម្បីរក្សា និងកែលំអជីជាតិដី ? តើធ្វើរបៀបណាដើម្បីរក្សា និងកែលំអជីជាតិដី ?
- ✧ តើដំណាំដែលយកមកធ្វើជារបងរស់អាចផ្តល់ផលប្រយោជន៍បានច្រើនឬទេ ?
  ឧទាហរណ៍ : ឱសថបុរាណ ខ្សែចងផ្សេងៗ ផ្កាលំអ ។ល។
- ✧ តើគ្រួសារទាំងនោះបានប្រើប្រាស់កាកសំណល់ទឹក ទឹកពីចង្ក្រានបាយ ទឹកនោម និង លាមកសត្វពាហនៈ ដើម្បីយកមកប្រើប្រាស់សំរាប់ដាំដុះឬទេ ? បើប្រើប្រាស់តើគេប្រើបាស់យ៉ាងដូចម្តេច ? មានអនាម័យត្រឹមត្រូវឬទេ ?

ប្រសិនបើយើងឃើញមានកន្លែងនៅចោលទំនេរច្រើន (មិនដាំដុះ) យើងត្រូវពិភាក្សាជាមួយប្រជាជនរកហេតុផល ។ ហេតុផលខ្លះដែលប្រជាជនលើកឡើងគឺ បញ្ហាខ្វះទឹក ខ្វះគ្រាប់ពូជ មួប់ច្រើនពេក ពិបាកក្នុងការការពារសត្វមាន់ និងជ្រូក ។ល។ កុំឲ្យបំផ្លាញដំណាំ ។ ទាំងអស់នេះហើយគឺជាបញ្ហា ប៉ុន្តែបញ្ហាទាំងនេះអាចដោះស្រាយបាន ប្រសិនបើយើងគិត និងធ្វើការរួមគ្នាជាមួយគាត់ ហើយមិនបោះបង់ការព្យាយាមចោល




រូបភាពទី ១ : ប្រភេទដំណាំបន្លែដែលមានដាំតាមរដូវផ្សេងៗគ្នា

រូបភាពទី ២ : សួនដំណាំបង្ហាញអំពីដំណាំមួយចំនួន និងដើមឈើ





រូបភាពទី ៣ : រូបភាពសួនជុំផ្ទះ

ឆាប់ពេកនោះ ។ បច្ចេកទេស និងវិធីខ្លះៗ ក្នុងការដោះស្រាយបញ្ហាទាំងនេះ នឹងមានពន្យល់នៅទំព័របន្ទាប់ ។ អ្នកត្រូវតែសិក្សា និងពិភាក្សាទៅលើវិធីសាស្ត្រទាំងនោះ ហើយធ្វើការសាកល្បង ។

ប្រសិនបើយើងរៀបចំប្លង់សួនបានល្អ គ្រប់គ្រងដី និងទឹកបានត្រឹមត្រូវ ជ្រើសរើសដំណាំសំរាប់រដូវនិមួយៗ និងសមស្របតាមលក្ខខ័ណ្ឌធម្មជាតិរបស់ភូមិដោយប្រុងប្រយត្ន័ នោះយើងនឹងមានបន្លែ ផ្លែឈើជាអាហារនៅគ្រប់រដូវ ហើយបរិស្ថានជុំវិញផ្ទះនឹងស្អាត ព្រមទាំងកេនអនាម័យ សមាជិកគ្រួសារនឹងពេញចិត្តក្នុងការថែសួន និងមានសុខភាពល្អ ។

## ៣. ដីល្អ (វិធីក្នុងការសំគាល់ដី)

> <u>គោលបំណង</u> :
>
> *បន្ទាប់ពីរៀនជំពូកនេះចប់ អ្នកនឹងអាច :*
>
> - ដឹងថាតើមានចំណុចអ្វីខ្លះ ដែលអាចឲ្យយើងសំគាល់បានថាដីដែលមានជីជាតិល្អ
> - រៀនដឹងអំពីធាតុផ្សំសំខាន់ៗរបស់ដី

រុក្ខជាតិដែលយើងអាចដាំបាននៅក្នុងសួន បញ្ហាធំបំផុតគឺអាស្រ័យទៅលើប្រភេទដី ។ បន្លែ និងដំណាំហូបផ្លែភាគច្រើនទាំងអស់ត្រូវការដីគ្មានថ្ម និងយ៉ាងតិចណាស់ស្រទាប់លើមានជំរៅពី ៣០ ទៅ ៥០ ស.ម ដែរ ។

យើងអាចសំគាល់ដីដែលមានជីជាតិល្អបាន ដោយធ្វើការអង្កេតលើចំណុចសំគាល់មួយចំនួន និងធ្វើការពិសោធន៍ដោយវិធីងាយៗ ។ ចំណុចសំរាប់ជួយឲ្យយើងសំគាល់ដីល្អ មានដូចខាងក្រោមនេះ ៖

- ដីល្អ ងាយស្រួលជីក ហើយមានរាងជាដុំតូចៗ ដែលស្អិតជាប់គ្នា
- នៅក្នុងដីល្អមានសរីរាង្គមានជីវិតជាច្រើន ឧទាហរណ៍ សត្វជន្លេន និងសត្វល្អិតផ្សេងៗទៀត
- ដីល្អមានពណ៌ក្រមៅ ហើយមានក្លិនល្អ (ក្លិនប្រហើរ)
- ប្រសិនបើទុកដីល្អឲ្យនៅទំនេរ (មិនដាំដុះ) ក្នុងពេលដ៏ខ្លីវានឹងមានស្មៅជាច្រើនដុះ
- ទឹកដែលហូរចេញពីដីល្អមានពណ៌ថ្លា

ដីផ្សំឡើងដោយសារធាតុរ៉ែ សារធាតុសរីរាង្គ និងចន្លោះទំនេរដែលមានរន្ធខ្យល់និងទឹក ។ ស្ទើរតែពាក់កណ្តាលនៃបរិមាណដីផ្សំឡើងដោយសារធាតុរ៉ែ ។ ទឹក ខ្យល់ និងកំដៅថ្ងៃបំបែកថ្មជាបំណែកតូចៗ ឬជាល្បាយដោយប្រើរយៈពេលយ៉ាងយូរ ។ បំណែកថ្ម ឬល្បាយនេះ គេហៅថាធាតុរ៉ែរបស់ដី ។ ធាតុរ៉ែជាមួយនឹងការរលួយរុក្ខជាតិ និងសត្វ ។ តាមរបៀបនេះ ដីត្រូវបានកកើតឡើងដោយប្រើរយៈពេលយ៉ាងវែង ។

អាស្រ័យទៅលើទំហំរបស់វា គេហៅធាតុរ៉ែរបស់ដី ថាខ្សាច់ ល្អដ្ឋ ឬល្បាយខ្សាច់ ។ សមាសភាពរបស់ខ្សាច់ ល្អដ្ឋ និងល្បាយខ្សាច់កំណត់នូវវាយនភាព និងសមត្ថភាពក្នុងការរក្សាទុកនូវទឹក និងសារធាតុចិញ្ចឹម ។

៥% នៃដីចន្លោះ ត្រូវបានបំពេញដោយសារធាតុសរីរាង្គ ឬសរុក្ខជាតិ កំទេច និងលាមកសត្វ សត្វល្អិត និងសារធាតុសរីរាង្គតូចៗ ។ល។ សារធាតុទាំងអស់នេះធ្វើឲ្យដីជាប់គ្នាហើយនិងកំណត់នូវទំរង់ដី ។

ពាក់កណ្តាលទៀតនៃដី គឺជាចន្លោះតូចៗដែលត្រូវបានបំពេញដោយខ្យល់ និងទឹក ។ ខ្យល់នៅក្នុងដីមានសារៈសំខាន់ណាស់សំរាប់ការលូតលាស់ល្អរបស់ដំណាំ ។ ដីមានសារៈសំខាន់ណាស់សំរាប់សុខភាពរបស់ដំណាំ ។

អាហាប
និងធ្វើ
ត
ស្មើរតែ
តូចៗ ឬជា
ជាមួយនឹង
។
សមាសភាគ
និងសារធាតុ
តូ សត្វល្អិត
ខ្យល់នៅក្នុងដី
សុខភាពរបស់




រូបភាពទី ៤ : ដីស្រទាប់លើ និង ដីស្រទាប់ក្រោម

គុណភាព ឬជីជាតិរបស់ដីតែងតែត្រូវបានបង្កើន ឬថយចុះ ដោយអាស្រ័យទៅលើគំរបរបស់រុក្ខជាតិដែលមានទៅលើដី របៀបកាប់គាស់ភ្ជួររាស់ របៀបដាំ និងស្រោចទឹក ប្រភេទនៃដី និងថ្នាំសំលាប់សត្វល្អិតដែលបានប្រើ ។ល។

គេអាចធ្វើការវិភាគដីតាមរបៀបសាមញ្ញ ដូចជាការវិភាគ ដោយយកដីទៅក្រឡុកក្នុងដប ហើយទុកក្នុងរយៈពេលកំណត់មួយ ដើម្បីសង្កេតមើលសមាសធាតុរបស់ខ្សាច់ ឥដ្ឋ ល្បាយ និងសារធាតុសរីរាង្គ

## ៤_ ការថែរក្សា និង កែលំអជីជាតិដី

<u>តើដីអាចត្រូវខូចខាតដោយរបៀបណាខ្លះ ?</u>

**<u>គោលបំណង</u> :**

*បន្ទាប់ពីរៀនជំពូកនេះចប់ អ្នកអាចយល់បានថា :*

- ឫសហេតុដែលនាំឲ្យដីបាត់បង់ជីជាតិ
- គំនិត និងបច្ចេកទេសសំខាន់ៗ សំរាប់យកទៅអនុវត្តក្នុងការកែលំអដី

ការកកើតនូវដីដែលមានជីជាតិត្រូវការពេលវេលាយូរណាស់ ក៏ប៉ុន្តែដីអាចត្រូវបាត់បង់ ឬខូចខាតនូវគុណភាពវិញ ក្នុងរយៈពេលខ្លី ។ កត្តា និងសកម្មភាពសំខាន់ៗដូចខាងក្រោមនេះ អាចនាំឲ្យដីមានការខូចខាត :

- ដាំដំណាំឫសខ្លី ឬដំណាំត្រូវការជីជាតិច្រើនបន្តបន្ទាប់គ្នាច្រើនសា ។ ការនាំចេញនូវកាកសំណល់រុក្ខជាតិ
- ការប្រើប្រាស់ជី និងជីគីមីខុសរបៀប ឬច្រើនហួស
- ប្រើថ្នាំគីមីសំលាប់សត្វល្អិត ថ្នាំសំលាប់ផ្សិត ឬថ្នាំសំលាប់ស្មៅនិងរុក្ខជាតិដុះរាង ។ល។
- ការចំហដីត្រូវកំដៅថ្ងៃខ្លាំងដែលអាចនាំឲ្យមានកំរិតរំហួតខ្ពស់ និងមានសកម្មភាពសារពាង្គកាយក្នុងដីតិច
- សំណឹក ឬការបាត់បង់ដីស្រទាប់លើដោយខ្យល់និងទឹកភ្លៀង
- ដីឡើងហាប់ដោយសារការភ្ជួររាស់ខ្លាំង និងញឹកញាប់ពេក ដោយទំងន់មនុស្ស សត្វ ឬការដាំក្លាស់នៃដំណាំមិនបានត្រឹមត្រូវ ឬរបៀបស្រោចទឹកមិនបានសមស្រប ។ល។

នៅពេលគុណភាពដីត្រូវបានថយចុះដោយភាពហាប់ ភាពហូរច្រោះដីស្រទាប់លើ ។ល។ រុក្ខជាតិដែលដុះនៅលើដីនោះនឹងមានជំងឺ ឬមិនអាចលូតលាស់បានល្អ ហើយងាយទទួលនូវការបំផ្លាញពីកត្តាចង្រៃផ្សេងៗ ។ ពេលនោះផលដំណាំនឹងថយចុះ ហើយអ្នកម្ចាស់សួនបាត់បង់ទឹកចិត្ត ។ ជួនកាលដីត្រូវបាត់បង់ជីជាតិអស់ ឬសំបូរដោយជាតិពុលដែលមិនអាចជួយដល់រុក្ខជាតិដុះបាន ហើយក្លាយទៅជាវាលលំហ ។

ដើម្បីធានាឲ្យបាននូវការធ្វើសួនដំណាំដែលមានទិន្នផលខ្ពស់ ហើយយូរអង្វែង ការថែរក្សា និងកែលំអជីជាតិដីជាការឬយចាំបាច់ណាស់ ។




រូបភាពទី ៧ : *មីក្រូសរីរាង្គក្នុងដី (ដីមានជីវិត)*




រូបភាពទី ៤ : របៀបតេស្តដីមើលវាយនភាព និង សារធាតុសរីរាង្គរបស់ដី

**ការបង្កើន ឬការកែលំអគុណភាពដី**

ធ្វើការថែរក្សា និងកែលំអគុណភាពដីតាមរបៀបផ្សេងៗ ដូចជា ៖

- ការប្រមូលកាកសំណល់សរីរាង្គ ឬរុក្ខជាតិឡើងវិញដើម្បីធ្វើជាជី ដូចជា ជីកំប៉ុស្តគោក និងជីកំប៉ុស្តទឹក
- ដាំដំណាំដែលជួយបង្កើនគុណភាពដី និង ប្រើជីដែលបានមកពីស្លឹករុក្ខជាតិ
- ដាំដំណាំឆ្លាស់ និង ដាំចំរុះជាមួយពពួកសណ្តែក ឬពពួកគួរ

**ការបន្ថយនូវសំណឹកដីគ្រោះថ្នាក់ តាមរយៈការហូរចេញ និងតាមរយៈខ្យល់**

- ការគ្របដី ដាំដំណាំ ឬពពួកស្មៅដែលមានប្រយោជន៍គ្របដី
- ការកែប្រែដីដោយប្រើអង្កាម ធ្យូង ដាក់ទៅក្នុងដីឥដ្ឋ ឬដាក់ជីកំប៉ុស្តក្នុងដីខ្សាច់ ។ល។
- ធ្វើរណាប់ព្រៃ សួនរង្វង់ សំរាប់ដាំដំណាំ
- ដាំរុក្ខជាតិជារបងរស់ ឬដាំដើមឈើលើផ្ទៃដីរបស់សួន ដើម្បីធ្វើជារបាំងខ្យល់




អាចយកទៅប្រើបានក្រោយរយៈពេលពី ៣_៤ អាទិត្យ ។ បើរក្សាទុក
ក្នុងម្លប់ អាចយកទៅប្រើបានក្រោយរយៈពេល ៥_៦ អាទិត្យ ។

ជីកំប៉ុស្តរាវប្រហែល ១ លីត្រ អាចស្រោចស្រពដំណាំលើផ្ទៃដី ១ ម$^2$
ហើយស្រោចស្រពជារៀងរាល់សប្តាហ៍ ជាតំរូវការសមស្របសំរាប់ដំណាំ
បន្លែទូទៅ ។ គេអាចចាក់ផ្ទាល់ទៅលើដី ឬលាយទឹកស្មើគ្នា មួយទល់មួយ
(ទឹក ១ លីត្រ លាយជី ១ លីត្រ) ។ ដំណាំដែលបង្ហាញភោគខ្វះជីជាតិ
និងសួនបណ្តុះកូនដំណាំ គួរស្រោចស្រពឲ្យបានញឹក (២_៣ ដងក្នុង ១ សប្តាហ៍)

រូបភាពទី ៩ : ការរៀបចំធ្វើជីកំប៉ុស្តរាវ




- ការរៀបជាស្រទាប់ៗ មិនទាមទារឲ្យយើងត្រឡប់ទេ (ការត្រឡប់មិនចាំបាច់ទេ)
- ត្រូវឧស្សាហ៍ស្រោចទឹកបន្ថែម ជាពិសេសនៅខែប្រាំង ដើម្បីឲ្យសារធាតុឆាប់រលួយ តែជៀសវាងកុំស្រោចឲ្យជោគពេក ។
- អាចយកមកប្រើបានក្រោយរយះពេល ៣ ខែ ឡើងទៅ គឺនៅពេលដែលសារធាតុទាំងនោះរលួយចូលគ្នាអស់ ដោយមិនអាចឲ្យយើងស្គាល់បានថា តើធាតុណាជាធាតុអ្វី ។



រូបភាពទី ១១ : ជីស្លឹកឈើស្រស់



រូបភាពទី ១២ : ដំណាំចំរុះ



របៀបកាត់ដើម្បីឲ្យបែកមែក
ដោយកាត់ត្រឹមកំពស់ស្មាយើង



របៀបដើម្បីឲ្យបែកមែកច្រើន
(កាប់មែកដោយខិតចុះមកក្រោម
ឲ្យមកកៀកដីបន្តិច)

រូបភាពទី ១៣ : *របៀបកាប់មែកយកស្លឹកធ្វើជីស្រស់*



រូបភាពទី ១៤ : ដំណាំបណ្ដាក់/មទ្ទិល



រូបភាពទី ១៥ : របៀបដាំកូនឈើ



រូបភាពទី ១៦ : របៀបរក្សាសំណើមដីដោយការប្រើចំបើង ហើយនិងគ្របរង



រូបភាពទី ១៧ : ស្នូតខ្ទង់



រូបភាពទី ១៨ : ការដាំរុក្ខជាតិជាជួររបាំងនៅលើដីដែលមានចំណោត

## ៥_ ដំណាំ និង ទឹក

**គោលបំណង :**

*បន្ទាប់ពីអានជំពូកនេះចប់ អ្នកអាចដឹងបានថា :*

☞ តើតំរូវការទឹករបស់ដំណាំវាអាស្រ័យទៅលើកត្តាអ្វីខ្លះ ?

☞ អ្វីទៅជាសមត្ថភាពរបស់ដីក្នុងការរក្សាសំណើម និងសារៈសំខាន់របស់វា ដល់ការលូតលាស់របស់ដំណាំ ?

☞ បច្ចេកទេស ឬគំនិតសំខាន់ៗសំរាប់យកទៅអនុវត្តនៅពេលដាំដុះ ក្នុងស្ថានភាពខ្វះខាតទឹក ?

### តំរូវការទឹកនៃដំណាំ

បរិមាណទឹកដែលយើងត្រូវការស្រោចដំណាំវាអាស្រ័យទៅលើប្រភេទនៃដំណាំ រដូវកាល និងលក្ខណៈធម្មជាតិរបស់ដី ។

១_ ប្រភេទដំណាំ : ជំរៅរបស់ឫស និងដំណាក់កាលនៃការលូតលាស់

២_ បំរែបំរួលតាមរដូវ : កំដៅ (សីតុណ្ហភាព) ថ្ងៃ ល្បឿននៃខ្យល់ សំណើមរបស់ខ្យល់ និង បរិមាណទឹកភ្លៀង

៣_ ធម្មជាតិរបស់ដី : ទំរង់និងជំរៅរបស់ដី និងវាយនភាពរបស់ដី

### ទឹកនៅក្នុងដី

- សមត្ថភាពនៃការរក្សាទឹកទុករបស់ដីអាស្រ័យសំខាន់បំផុតទៅលើទំរង់ វាយនភាពរបស់ដី និងបរិមាណរបស់សារធាតុសរីរាង្គដែលមាននៅក្នុងដី
- ដីខ្សាច់ស្រូបយកទឹកបានលឿន ប៉ុន្តែទឹកទាំងនោះ ភាគច្រើនត្រូវបាត់បង់ទៅវិញតាមការហូរចុះទៅក្រោម ។ ដីឥដ្ឋ ស្រូបទឹកយឺតៗ ហើយបញ្ចេញទឹកវិញមានល្បឿនយឺតៗ ដែរ ។ ដីឥដ្ឋភាគច្រើនមានបញ្ហាក្នុងការបញ្ចេញទឹកចេញ
- បរិមាណនៃសារធាតុសរីរាង្គនៅក្នុងដីក៏មានឥទ្ធិពលទៅលើសមត្ថភាពរក្សាទឹករបស់ដីដែរ
- ដីដែលមានស្រទាប់រាក់មិនអាចឲ្យឫសរបស់រុក្ខជាតិលូតលាស់បានល្អ ហើយត្រូវការការស្រោចទឹកឲ្យបានញឹកញាប់



នៅពេលរុក្ខជាតិ
ដុះលូតលាស់វា
ស្រូបទឹកពីឆ្ងាយ
និងពីស្រទាប់ដីជ្រៅ

| | | | |
|---|---|---|---|
| កូនរុក្ខជាតិដែល[illegible] ឫស[illegible] | កូនឈើត្រូវដកយក ទៅដាំ | រុក្ខជាតិចេញផ្កា_ផ្លែ ការលូតឫសជ្រៅ | រុក្ខជាតិមានផ្លែ ឫសជ្រៅ |
| ត្រូវការទឹកតិច ប៉ុន្តែ[illegible] ស្រោចពីរដងក្នុងមួយថ្ងៃ | ត្រូវការទឹកតិចដែរ - ស្រោចទឹកម្តងក្នុងមួយថ្ងៃ | ត្រូវការទឹកច្រើន ក្នុងពេលចេញផ្កា ២_៣ ដង/អាទិត្យ | ត្រូវការទឹកល្មម ១_២ ដង/អាទិត្យ |



តម្រូវការទឹកមធ្យមចំពោះដំណាំបន្លែ តាមដំណាក់កាលលូតលាស់របស់ដំណាំ

| | | | |
|---|---|---|---|
| រដូវក្តៅ / ស្ងួត | ២០ ទៅ ២៤ លីត្រ /ម²/ អាទិត្យ ពេលនៅតូច (ដំណាក់កាលដំបូង) | [illegible] ទៅ [illegible] លីត្រ /ម²/ អាទិត្យ | ២៥ ទៅ ៣០ លីត្រ /ម²/ អាទិត្យ |
| រដូវសើម / ត្រជាក់ | ១៥ ទៅ ២០ លីត្រ /ម²/ អាទិត្យ | [illegible] ទៅ [illegible] លីត្រ /ម²/ អាទិត្យ | ២៦ ទៅ ២៨ លីត្រ /ម²/ អាទិត្យ |

រូបភាពទី ១៩ : តម្រូវការទឹកមធ្យមចំពោះដំណាំបន្លែ តាមដំណាក់កាលលូតលាស់របស់ដំណាំ

- សមត្ថភាពក្នុងការបង្ហូរច្រោះទឹក គេសំដៅសមត្ថភាពរបស់ដីក្នុងការបង្ហូរទឹកបញ្ចេញដោយខ្លួនឯង ។ ដីដែលមិនអាចឲ្យទឹកបង្ហូរច្រោះបានល្អឬដីដែលជាំទឹកអាចបណ្តាលឲ្យដំណាំដុះលូតលាស់មិនល្អ និងទទួលបានទិន្នផលទាប ។ នេះដោយសារមូលហេតុដូចខាងក្រោម ៖
  - ការខ្វះខាតនូវអុកស៊ីសែន (ឬខ្យល់ដកដង្ហើម) បង្អាក់នូវការដុះលូតលាស់របស់ឫសដំណាំ
  - ការខ្វះខាតអុកស៊ីសែនក្នុងដីបន្ថយនូវការលូតលាស់របស់មីក្រូសរីរាង្គមានជីវិតសំខាន់ៗ (សត្វល្អិត) ក្នុងដី និងបង្កលក្ខណៈឲ្យសរីរាង្គមានជីវិតមិនល្អ (គ្មានប្រយោជន៍) កកើតច្រើន ។

## ការដោះស្រាយជាមួយស្ថានភាពខ្វះខាតទឹក

ទឹកជាកត្តាមួយយ៉ាងសំខាន់សំរាប់ការលូតលាស់របស់ដំណាំ ។ នៅពេលដែលដំណាំមិនបានទទួលទឹកគ្រប់គ្រាន់ ស្លឹករបស់វានឹងរបូរចូលក្នុង ឬជ្រុះ ។ រុក្ខជាតិចាប់ផ្តើមស្វិត ឬស្រពោនដោយសារការខ្វះសំណើម នៅក្នុងរុក្ខជាតិ ហើយទិន្នផលក៏មានការថយចុះយ៉ាងខ្លាំងដែរ ។ បញ្ហានេះគេច្រើនតែជួបប្រទះនៅរដូវខ្វះខាតទឹក ជាពិសេសនៅរដូវមួយមានភាពរាំងស្ងួត អាកាសធាតុក្តៅខ្លាំង ហើយមានរំហួតខ្ពស់ ។

ក៏ប៉ុន្តែ នៅក្នុងស្ថានភាពខ្វះខាតទឹក គេក៏អាចធ្វើការដាំដុះបានប្រសិនបើគេចេះអនុវត្តនូវបច្ចេកទេសសមស្របល្អ ។ មានបច្ចេកទេសសំខាន់ៗ មួយចំនួនសំរាប់អនុវត្តក្នុងការដោះស្រាយកង្វះខាតទឹក ដូចជា :

- ការគ្របដី
- ជ្រើសរើសរុក្ខជាតិដែលធន់នឹងភាពស្ងួតសំរាប់ដាំ
- ដាំដំណាំច្រើនជាន់ ឬដាក់ដាំដំណាំកៀកៗគ្នា ដើម្បីងាយស្រោចទឹកតែមួយកន្លែង
- ការប្រមូលទឹកភ្លៀង ឬស្តុកទឹកភ្លៀងទុកលើស្លួន និងក្នុងដីរបស់ស្លួន
- ការប្រើទឹកដែលជាកាកសំណល់សំរាប់ស្រោចលើដំណាំ
  (ឧទាហរណ៍ ទឹកដែលប្រើលាងចានហើយ)
- ការដាំដំណាំដែលមានតំរូវការទឹកដូចគ្នានៅជិតៗគ្នា
- ស្រោចរបៀបជាដំណក់ៗ ឬស្រោចនៅតាមស្រទាប់ដីខាងក្រោម (ឧទាហរណ៍ បំពង់ទុយោ ឬទុយោ ដែលមានប្រហោងតូចៗ)

កាលណាដីជាំទឹកពេក ឬត្រូវទទួលរងការលិចទឹកក្នុងរយៈពេលយូរ ឬខ្លី វាគឺជាបញ្ហាមួយដល់ការធ្វើស្លួនដែរ ។ ក្នុងករណីគេជួបបញ្ហាទឹកច្រើនពេក យើងអាចដោះស្រាយតាមរបៀបខ្លះៗ ដូចខាងក្រោមនេះ ៖

១ ប្រសិនបើតំបន់នោះមិនមែនទំនាបលិចទឹក ប៉ុន្តែមានទឹកដក់ដោយសារដីហាប់ ការបង្កើនសមត្ថភាពបង្ហូរទឹកចេញរបស់ដី (ឬការកាត់បន្ថយភាពជាំទឹក ឬដក់ទឹក) អាចជួយដោះស្រាយបញ្ហានេះបាន ។
ឧទាហរណ៍ គេអាចលើករង ឲ្យខ្ពស់ ឬបំបែកដី ឬបំផុសស្រទាប់រឹងនៅផ្នែកខាងក្រោមរបស់ដី ។ល។



| | | |
|---|---|---|
| បរិមាណទឹកដែលមានលើផ្ទៃដី ១ម$^2$ ចំពោះស្រទាប់ខាងលើនៃដីខ្សាច់ ៨.១៦ លីត្រ | បរិមាណទឹកដែលមានលើផ្ទៃដី ១ម$^2$ ចំពោះស្រទាប់ដីមានជីជាតិល្អ ៣២.៤០ លីត្រ | បរិមាណទឹកដែលមានលើផ្ទៃដី ១ម$^2$ ចំពោះដីឥដ្ឋស្រទាប់លើ ៥៦.៦៤ លីត្រ |




អាស្រ័យលើប្រភេទភាគដី បរិមាណទឹកដូចគ្នា ការជ្រាបទឹកចូលក្នុងដីទៅតាមជំរៅផ្សេងៗគ្នា ។ នេះបានន័យថា ជារុក្ខជាតិដែលមានឫសជ្រៅអាចរស់បានល្អនៅលើដីខ្សាច់ ។ រុក្ខជាតិដែលមានឫសរាក់ អាចប្រើប្រាស់ទឹកបាន ត្រឹមតែ ២០-២៥% នៃទឹកដែលផ្តល់ឲ្យរុក្ខជាតិ ។

រូបភាពទី ២០ : *សមត្ថភាពរបស់ដីក្នុងការស្តុកទឹកក្នុងស្រទាប់ដី*

ជីកដីដែលមានជំរៅ ៦០ × ៦០ × ៧៥ ស.ម ចាក់ទឹក
បំពេញ ១-២ ម៉ោងក្រោយ ទឹកជ្រាបបាត់អស់




រុក្ខជាតិក្រិន មានពណ៌លឿងស្លេក
ជាដីប្រហែលជាកករ រឺ មិនស្រូប
ជ្រាបទឹក

ចាក់ទឹកបន្ថែមក្នុងរណ្តៅលើកទី ២ ប្រសិនបើពី ២០-២៤ ម៉ោង ទឹករីងស្ងួតមានន័យថា សមត្ថភាពនៃការជ្រាបទឹកមានលក្ខណៈល្អ ។ ប្រសិនជាវាប្រើរយៈពេលយូរជាងនេះ យើងត្រូវបន្ថែមធ្យូង, អង្កាម, ឬសារធាតុស្រដៀងគ្នាចូលក្នុងដី ។ ប្រសិនបើទឹករីងឆាប់ពេក យើងត្រូវបន្ថែមកំប៉ុស្ត ស្លឹកឈើស្រស់ ភក់ ដើម្បីបង្កើនសមត្ថភាពស្រូបយកទឹករបស់ដី ។ ការសាកល្បងនេះ មិនអាចយកជាការបាន (ជឿជាក់បាន) ប្រសិនបើដីនេះរឹង ឬក៏ហាប់ណែនទៅចន្លោះស្រទាប់ដីលើ និងស្រទាប់ដីកណ្តាល ។

ទឹកដក់ក្រោយពេលភ្លៀង ច្រើនថ្ងៃ
ហើយនឹងជាដីស្រែ ឬដីដែលមិន
ជ្រាបទឹកល្អ

រូបភាពទី ២១ : *ការតេស្តមើលលក្ខណៈរបស់ដីក្នុងការបង្ហូរទឹកចុះក្រោម (តើដីជាំទឹកខ្លាំង ឬមិនជាំទឹក)*



រូបភាពទី ២២ : ការគ្របដីដោយស្រទាប់រុក្ខជាតិស្ងួត ឬស្មៅ ចំបើង ឬជី គេបង្ការការបាត់បង់សំណើមក្នុងដី




រូបភាពទី ២៣ : រុក្ខជាតិដែលគេដាំគ្របពីលើការពារដី (ឧទាហរណ៍ខ្លះៗ)



រូបភាពទី ២៤ : ដំណាំត្រឹតជាន់



រូបភាពទី ២៥ : ស្នូកខ្ទប់ដែលមានដំណាំជុំះ



រូបភាពទី ២៦ : ការប្រើប្រាស់ទឹកជាកាកសំណល់សំរាប់ស្រោចដំណាំ



រូបភាពទី ២៧ : របៀបដាំក្នុងករណីខ្វះខាតទឹក ប្រព័ន្ធស្រោចដោយប្រើក្អម ឬដប



រូបភាពទី ២៨ : រងដែលកាប់ជ្រៅ ហើយបំពេញដោយសារធាតុសរីរាង្គ



រូបភាពទី ២៩ : សួនកង់ឡាន



រូបភាពទី ៣០ : របៀបដាំ[illegible] ប្រឆាំងនឹងទឹកជំនន់




រូបភាពទី ៣១ : របៀបដាំដំណាំលើដីដែលជាំទឹក [illegible]

- ប្រសិនបើទឹកនៅក្រោមដីមានកំរិតខ្ពស់ ឬស្ទឹងដែលកើតទឹកគ្រប់រដូវ នោះយើងអាចដាំនៅលើដីទួលខ្ពស់ គំនរដី ឬលើករងដាំដំណាំក៏បាន
- នៅទីទាបដែលត្រូវលិចទឹករយៈពេលខ្លី ឬវែង យើងចាំបាច់ត្រូវលើកប្រឡាយតូចៗ ឬស្រះ ឬលើកជាភ្លឺ ហើយដាំដំណាំនៅលើប្រឡាយ ឬភ្លឺទាំងនោះ ។
- គេជ្រើសរើសដំណាំណាដែលសមស្រប ឬអាចដុះលូតលាស់បានល្អ នៅពេលមានទឹកដក់ ឬអាចធន់នឹងភាពជាំទឹក

## ៦_ ការជ្រើសរើសដំណាំ

<u>គោលបំណង</u> :

*បន្ទាប់ពីអានជំពូកនេះចប់ អ្នកអាចដឹងបានថា :*

១ តើមានចំណុចអ្វីខ្លះដែលអាចជួយឲ្យយើងធ្វើការវិនិច្ឆ័យ ដើម្បីសំរេចចិត្តជ្រើសរើសប្រភេទដំណាំមួយ មកដាំក្នុងសួន ?

### <u>ការជ្រើសរើសដំណាំទៅតាមប្រភេទដី</u>

១ <u>ការជ្រើសរើសឲ្យសមស្របទៅតាមប្រភេទដី</u>

ការជ្រើសរើសដំណាំឲ្យសមស្របទៅតាមប្រភេទដី គឺជាគន្លឹះក្នុងការធ្វើឲ្យសួនដំណាំទទួលបានជោគជ័យ ។ ដំណាំប្រភេទផ្សេងៗគ្នា (ហើយជួនកាលពូជផ្សេងគ្នា) ត្រូវការទឹក សារធាតុចិញ្ចឹម ពន្លឺថ្ងៃ ។ល។ ខុសៗគ្នា និងមានកំរិតនៃភាពធន់នឹងដីជាតិអាស៊ីត (ជាតិជូរ) ដីជាតិបាស (ជាតិផ្អែម) ភាពរាំងស្ងួត ភាពលិចទឹក ឬជាតិទឹករបស់ដី ជំងឺ និងការបំផ្លាញដោយសត្វល្អិតផ្សេងៗគ្នា ។

២ <u>ការរើសដំណាំទៅតាមតំរូវការសារធាតុចិញ្ចឹម **(ឬជីជាតិដី)**</u>

បន្លែស្លឹក ដូចជាស្ពៃ ជ្រលង់ ត្រកួន និងបន្លែមានផ្លែ ដូចជាល្ពៅ ប៉េងប៉ោះ ត្រប់ ។ល។ គឺជាដំណាំដែលត្រូវការជីច្រើន ។

ដំណាំមើម ដូចជាដំឡូងជ្វា ដំឡូងបារាំង ត្រាវ ។ល។ ត្រូវការជីតិចល្មម ។ ពពួកសណ្តែកត្រូវការជីតិចជាងគេ ហើយជាញឹកញាប់ ដំណាំប្រភេទនេះផ្តល់ជីដល់ដំណាំផ្សេងទៀតដែលដាំបន្ទាប់ពីពពួកសណ្តែកនេះ ។ ការដាំដំណាំឆ្លាស់តាមរដូវ (ការដាំបង្វិល) មានសារៈសំខាន់ក្នុងការថែរក្សាជីជាតិដី និងកាត់បន្ថយនូវការកើតមានជំងឺ ។

### <u>ជ្រើសរើសដំណាំទៅតាមវាយណភាពរបស់ដី</u>

ជាទូទៅ ដីខ្សាច់ល្អសំរាប់ដាំដំណាំអំបូរត្រសក់ ដូចជាល្ពៅ ឃ្លោក ប្រះ ឪឡឹក ។ល។ ដីបាយឬដីឥដ្ឋត្រូវនឹងពពួកសណ្តែក ។ ដំណាំមើម បន្លែហូបផ្លែ និងហូបស្លឹក ត្រូវការដីដែលមានជីជាតិល្អ ឬក៏ដីមិនឥដ្ឋពេក ឬមិនខ្សាច់ពេក ។

### <u>ជ្រើសរើសដំណាំឲ្យសមស្របទៅនឹងអាកាសធាតុ **(កំដៅ ពន្លឺថ្ងៃ រដូវកាល)**</u>

ការលូតលាស់ និងជាពិសេសការចេញផ្កានៃដំណាំភាគច្រើន គឺទទួលឥទ្ធិពលពីអាកាសធាតុជុំវិញ និងកំដៅដី ។ ភាពខុសគ្នារវាងកំដៅពេលថ្ងៃ និងពេលយប់ ក៏ជាសារៈសំខាន់សំរាប់ដំណាំមួយចំនួនដែរ ។ ការចេញផ្កានៃដំណាំ វាអាស្រ័យទៅលើរយៈពេលនៃថ្ងៃ ។ នៅពេលដែលយើងជ្រើសរើសដំណាំសំរាប់រដូវណាក៏ដោយ យើងត្រូវតែចងចាំនូវតំរូវការនៃការចេញផ្ការបស់ដំណាំទាំងនោះ ។ សរុបចំប្រតិទិននៃការដាំ និងការ



ពួកដំណាំដែលមានដើមវារ ឫស / មើម
ពួកបន្លែ (ដី ...) ដុះលូតលាស់ល្អលើដីខ្សាច់



បន្លែយកស្លឹក និងផ្លែ ភាគច្រើនដុះ
លូតលាស់ល្អលើដីឥដ្ឋ

| ៤ | ៥ | ៦ | pH ៧ | ៨ | ៩ |
|---|---|---|---|---|---|
| អាស៊ីតខ្លាំងបំផុត | អាស៊ីតខ្លាំង | អាស៊ីតខ្សោយ | ណឺត | អាល់កាឡាំង (ស្រាល) | អាល់កាឡាំងខ្លាំង [illegible] |
| រសជាតិដូចក្រូចឆ្មារ | ប៉េងប៉ោះ | ការ៉ុត | ទឹក | ប្រៃដូចទឹកសមុទ្រ | [illegible] |



រូបភាពទី ៣២ : *ការជ្រើសរើសដំណាំតាមជាតិដី*




រូបភាពទី ៣៣ : ការជ្រើសរើសដំណាំដាំតាមបង្គុំទៅការប្រើជាតិជី



ដំណាំរដូវក្តៅ
២៦-៣០°C
±៣°C



ដំណាំរដូវក្តៅល្មម
២១-២៥°C
±៣°C



ដំណាំរដូវរងា
១៥-២០°C
±៣°C

សីតុណ្ហភាពដី ជាកត្តាមួយយ៉ាងសំខាន់ក្នុងការកំណត់នូវការដុះពន្លករបស់គ្រាប់ ការរីកធំធាត់នៃឫស ការលូតលាស់របស់រុក្ខជាតិ ។ល។ ដីសើមតែងតែមានសីតុណ្ហភាពត្រជាក់ជាងបរិស្ថានខាងក្រៅ ៥°C ។

រូបភាពទី ៣៨ : *ការជ្រើសរើសដំណាំទៅតាមការសម្របនឹងកំដៅ (សីតុណ្ហភាព)*

- រុក្ខជាតិមានក្លិន (ជី)
- ខ្ទឹមបារាំង
- ការ៉ុត
- ត្រសក់
- ត្រសស់
- ស្ពៃខ្មៅ

- សណ្តែកគួរ
- ល្ហុក
- ល្ពៅ
- ម្ទេស
- ផ្ទី
- សណ្តែកសៀង

- ពពាយស្បែក
- ពោតបារាំង
- ដំឡូងជ្វា
- សណ្តែកអង្រៃ
- សណ្តែកអង្គុយ




រូបភាពទី ៣៨ : ប្រព័ន្ធឫសរបស់ដំណាំ

ប្រព្យផលសំរាប់ដំណាំដែលដាំនៅតាមបណ្ដោយភ្លឺ អាស្រ័យទៅតាមបទពិសោធន៍របស់កសិករ (មិនមែនកសិករដែលដាំដំណាំលើផ្ទៃដីធំៗសំរាប់លក់នោះទេ) ។

ដំណាំដែលមានឫសវែងៗ មិនត្រូវការស្រោចទឹកញឹកញាប់ទេ និងអាចធន់នឹងភាពរាំងស្ងួតបាន ។ មានតែបន្លែប្រចាំឆ្នាំតូចប៉ុណ្ណោះដែលអាចដាំបាននៅលើដីដែលសើមខ្លាំង ឬដីជាំទឹក ។

អ្នកចំការដែលដាំដំណាំលក់សំរាប់ធ្វើជំនួញ តែងតែដាំបន្លែដោយមិនសមស្របទៅនឹងអាកាសធាតុដើម្បីទទួលបានទិន្នផលខ្ពស់ ។ ដូច្នេះហើយ គេត្រូវការប្រើថ្នាំសំលាប់សត្វល្អិតជាច្រើន ។ នៅក្នុងសួនតាមគ្រួសារ យើងគប្បីជ្រើសរើសយកដំណាំណាដែលស្រួលដាំ ហើយសមស្របទៅតាមអាកាសធាតុរបស់តំបន់ និងរដូវកាលនិមួយៗ ។

## ការជ្រើសរើស និងដាំដំណាំឲ្យសមស្របទៅតាមទីតាំងដែលត្រូវដាំ

ក្នុងការជ្រើសរើសដំណាំសំរាប់ដាំនៅកន្លែង ឬទីតាំងណាមួយនៅក្នុងសួន យើងត្រូវការគិតគូរដល់រាង រៅ និង ទំហំរបស់ដំណាំ និងតំរូវការលើទឹក និងពន្លឺរបស់ដំណាំនោះ ។

ដំណាំប្រចាំឆ្នាំមិនអាចប្ដូរពីកន្លែងមួយទៅកន្លែងមួយទៀតដោយងាយនោះទេ ។ ហេតុដូចនេះ ពេលដែលយើងជ្រើសរើសកន្លែងសំរាប់ដាំដំណាំប្រភេទនេះ យើងត្រូវការពិនិត្យកន្លែងដាំ ថាតើទីនោះត្រូវសើមទឹក ឬអត់ នៅរដូវប្រាំង ។ រុក្ខជាតិខ្លះ ដូចជាដើមល្ហុងអាចរស់ដោយគ្រាន់តែត្រូវបានជាំទឹករយៈពេលខ្លីប៉ុណ្ណោះ ។

ត្រូវប្រុងប្រយ័ត្នក្នុងការដាំដើមឈើនៅកន្លែងណាមួយ ។ ដើមឈើអាចដើរតួនាទីជារបងសួន ឬជាជាំងការពារខ្យល់ ។ ដើមឈើក៏អាចផ្តល់នូវម្លប់ពេញសួនទាំងអស់ ឬក៏ផ្នែកណានៃសួន ហើយក៏អាចធ្វើជាទ្រើងសំរាប់ឲ្យដំណាំតាមរដូវ ឬដំណាំប្រចាំឆ្នាំវារឡើងបានដែរ ។

ដំណាំដែលត្រូវការស្រោចទឹកទៀងទាត់ និងតំរូវការការពារដូចគ្នាត្រូវដាំវានៅជិតៗគ្នា ។ [illegible] និងពី ខ្លះដុះលូតលាស់ល្អពេលដាំបញ្ចូលគ្នា ពួកដំណាំនេះហៅថាដំណាំគូកនគ្នា ឬដៃគូគ្នា ។



## ការជ្រើសរើសដំណាំដោយគិតដល់របៀបដាំពង្រីកបន្ត

ដំណាំភាគច្រើនដាំដោយគ្រាប់ ដំណាំខ្លះដាំដោយសាបគ្រាប់ផ្ទាល់តែម្ដង ខ្លះទៀតដាំដោយរបៀបផ្សេងៗគ្នាជាច្រើន និងគ្រាប់ខ្លះត្រូវការជ្រលក់ (ត្រាំ) ក្នុងទឹកត្រជាក់ ឬទឹកក្ដៅឧណ្ហៗសិនមុននឹងដាំ ដើម្បីជួយដល់ល្បឿននៃការលូតលាស់ និងចេញពន្លកស្រុះគ្នា ។

ទិន្នផលដំណាំអាចកើនឡើង និងឱកាសនៃការកើតជំងឺក៏ថយចុះដែរ ប្រសិនបើគេជ្រើសរើសគ្រាប់ពូជពីដំណាំដែលមានសុខភាពល្អ លាងគ្រាប់ និងហាលឲ្យស្ងួត និងរក្សាគ្រាប់ទាំងនោះទុកនៅកន្លែងដែលមានកំដៅ និងសំណើមទាប ។

ក្នុងសួនតាមគ្រួសារ យើងចង់បានដំណាំដែលងាយផលិតគ្រាប់ពូជ ឧទាហរណ៍ ត្រប់ ម្ទេស សណ្ដែក ល្ពៅ ឃ្លោក ត្រឡាច ត្រសក់ ។ល។ ដំណាំដែលដុះចេញពីគ្រាប់ជ្រុះចោលក៏មានប្រយោជន៍ដែរ ឧទាហរណ៍ ផ្ទី ជ្រលង់ ។ល។



ពួកដំណាំដែលត្រូវការពន្លឺព្រះអាទិត្យ



ដំណាំដែលធន់ទ្រាំនឹងម្លប់



ដំណាំដែលត្រូវការម្លប់

រូបភាពទី ៣៦ : ការបែងចែកដំណាំទៅតាមតម្រូវការពន្លឺ

សរីរាង្គលូតលាស់

មើម កាត់ឫស ។ល។



ការដាំរុក្ខជាតិដោយសរីរាង្គលូតលាស់មានការជ្រើសរើស



ដាំផ្នែកនៃគុម្ព
(បំបែក)

ដាំមើម ឬមើមតូចៗ



ដាំកំណាត់ដើម

ដាំមើម

ដាំក្បៀង

រូបភាពទី ៣៧ : ការបែងចែកដំណាំទៅតាមរបៀបដាំដុះ




រូបភាពទី ៣៨ : របៀបព្រោះ ដាំ និង ស្ទូង

ដំណាំខ្លះដាំដោយកាត់មែកទៅដាំ ដាំដោយបណ្តុះ ។ ដំណាំទាំងនេះងាយស្រួលក្នុងការដាំបន្ត ឧទាហរណ៍ ជ្រលង់ ត្រកួន ដំឡូងជ្វា ត្រាវ ដំឡូងឈើ ខ្ញី រមៀត ពីរក្រាប ។ល។ ដើមឈើហូបផ្លែក៏ដាំបន្តតាមមែកដែរ (ឧទាហរណ៍ កាប់មែកដោត ផ្សាំ បំពៅ) ដើម្បីបានទទួលផលលឿន និងបានផ្លែដូចគ្នា ។

* សរុបសេចក្តីមក យើងត្រូវជ្រើសរើសដំណាំណាដែលបំពេញលក្ខណៈ ដូចខាងក្រោមនេះ ៖
  - សមស្របទៅនឹងប្រភេទដីរបស់ស្អួន និងជីជាតិរបស់ដី
  - សមស្របទៅតាមអាកាសធាតុ និងរដូវកាល
  - សមស្របទៅនឹងទីតាំងដែលត្រូវដាំ
  - ងាយស្រួលក្នុងការផលិតពូជ

## ៧. ការការពារដំណាំ :

> <u>គោលបំណង</u> :
>
> *បន្ទាប់ពីអានជំពូកនេះចប់ អ្នកនឹងអាចបានយល់អំពី :*
>
> - គោលការណ៍ជាមូលដ្ឋានក្នុងការការពារដំណាំ
> - បច្ចេកទេស ឬគំនិតសំរាប់អនុវត្តក្នុងការការពារដំណាំ ប្រឆាំងនឹងសត្វល្អិត ជំងឺ និងសត្វស្រុកផ្សេងៗ

គោលការណ៍ជាមូលដ្ឋាន ដំណាំខ្លាំង ហើយមានសុខភាពល្អអាចដុះបានតែនៅលើដីដែលមានសុខភាពល្អដែរ ។ សត្វល្អិត និងជំងឺ គឺជារបៀបធម្មជាតិក្នុងការកំចាត់នូវដំណាំ ឬពូជដំណាំដែលមិនសមស្រប ។ សត្វល្អិតជាញឹកញយ គឺជាកត្តា ឬគ្រឿងសំគាល់ ដែលបង្ហាញនូវបញ្ហាដទៃៗទៀតដល់យើង ។ ដើម្បីបង្ការ[illegible]ខ្លាចរៀ ម្ចាស់សួនត្រូវតែដាំដំណាំឲ្យត្រូវនឹងរដូវ និងជ្រើសរើសយកតែគ្រាប់ដែលទុំល្អ និងមានពូជល្អ ហើយយកតែកូនដំណាំណាដែលមានសុខភាពល្អ និងរឹងមាំ មកដាំបន្ត ។

ការដាំដំណាំចំរុះ និងការដាំដំណាំផ្លាស់តាមរដូវ គឺជាវិធីដែលមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយនូវសត្វល្អិត ។ ពពួកពីជាច្រើនព្រមទាំងដំណាំដែលអាចប្រើជាឱសថបូរាណ មានផ្ទុកសារធាតុបណ្តេញសត្វល្អិតដែលរុក្ខជាតិទាំងនេះ ណាមួយជាមួយដំណាំបេកផល ឬប្រើប្រាស់វាជាថ្នាំសំរាប់ការពារដំណាំ ។ គោលបំណងរបស់យើងក្នុងការការពារដំណាំ គឺមិនមែនបំផ្លាញសត្វល្អិតឲ្យអស់ទាំងអស់នោះទេ ប៉ុន្តែយើងកាត់បន្ថយនូវចំនួន (បរិមាណ) របស់ពួកវាឲ្យនៅត្រឹមកំរិតមួយដែលវាមិនអាចបំផ្លាញផលដំណាំបានច្រើន ។ ការការពារ ឬបង្ការទុកជាមុន ជានិច្ចកាលយើងត្រូវយកចិត្តទុកដាក់ជាងគេ ដោយវាអាចជួយឲ្យយើងសំន្សំសំចៃប្រាក់កាស និងពេលវេលាបានយ៉ាងច្រើន ។

### <u>ការពារដំណាំប្រឆាំងនឹងសត្វល្អិត</u>

មានតែសត្វល្អិតមួយចំនួនតូចទេដែលធ្វើឲ្យខូចខាតដល់ដំណាំ ហើយក៏កើតមានតែក្នុងដំណាក់កាលខ្លះនៃវដ្តជីវិតរបស់សត្វល្អិតទាំងនោះ (ជាឧបមាគៅក្នុងដំណាក់កាលដែលទើបនឹងញាស់កូន) ។ សត្វល្អិតជាច្រើនជួយដល់ការបង្កើនទិន្នផលដំណាំដោយនាំលំអងទៅបង្កាត់ ។ សត្វល្អិតខ្លះស៊ីសត្វល្អិតដទៃទៀតជាអាហារ ដែលអាចជួយយើងក្នុងការកាត់បន្ថយចំនួនសត្វល្អិតបំផ្លាញ ។ ប្រសិនបើយើងអាចស្គាល់បាននូវសត្វល្អិតបំផ្លាញដំណាំ និងកំរិតនៃការបំផ្លាញរបស់ពួកវា គឺជាការសំខាន់ណាស់សំរាប់ការការពារ និងកំចាត់ ។

ថ្នាំសំលាប់សត្វល្អិតជាតិគីមីភាគច្រើនសំលាប់សត្វល្អិតមិនរើសមុខ ហើយជារឿយៗជួយដល់ការកកើតនៃសត្វល្អិតជំនាន់ទី ២ ។ ថ្នាំសំលាប់សត្វល្អិតផ្សំពីរុក្ខជាតិ ឧទាហរណ៍ ធ្វើអំពីថ្នាំជក់ ក៏មានផលអាក្រក់ដល់ពួកឃ្មុំ និងពពួកសត្វល្អិតដែលមានប្រយោជន៍ដទៃទៀតដែរ ។ ការធ្វើរបាំងការពារ ការបញ្ឆោតរុយ ដាក់អន្ទាក់



រើសគ្រាប់ពូជដែលបាក់បែក គ្រាប់ដែលមាន
ការបំផ្លាញពីសត្វល្អិត គ្រាប់ប្រេះស្រាំ ដាក់
ដោយឡែកពីគ្រាប់ដែលមានរូបរាងល្អ និងពណ៌ល្អ ។



ជ្រើសរើសគ្រាប់ពូជដែលនៅផ្នែកកណ្ដាល
នៃផ្លែ ចំពោះពពួកសណ្ដែក និងពួកគ្រាប់ធញ្ញជាតិ
(ឧទា. ពោត)



ជ្រើសរើសយកតែគ្រាប់ពូជណា
ដែលធ្ងន់លិចក្នុងទឹកយកទៅដាំ



ជ្រើសរើសតែកូនដើមរុក្ខជាតិណា
ដែលដុះត្រង់ និងរឹងមាំល្អ សំរាប់
ដកយកទៅដាំបន្តទៀត (ស្លូង)

រូបភាពទី ៣៩ : *គោលការណ៍សំខាន់ក្នុងការជ្រើសរើសគ្រាប់ពូជ និងកូនដំណាំ*

ការរក្សាទុកគ្រាប់ពូជ






គ្រាប់សណ្ដែកហាលឲ្យស្ងួតល្អ ហើយប្រឡាក់ប្រេងឆា (ប្រេងចំរាញ់ពីរុក្ខជាតិ) មុននឹងយកទៅរក្សាទុកនៅក្នុងដបកែវដែលបិទជិត

រូបភាពទី ៤០ : របៀបរក្សាទុកគ្រាប់ពូជ



រូបភាពទី ៤១ : ពពួកសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតខ្លះទៀតគ្មានប្រយោជន៍ (ខ្យង) នៅក្នុងស្រែចំការ



ស្លឹករុក្ខជាតិល្វីង រុក្ខជាតិមានក្លិនឈ្ងុយក្រអូប និងរុ
ពុល ត្រូវកិន ឬហាន់ឲ្យខ្ទេច ហើយត្រាំក្នុងទឹក ក្នុ
ពេល ២៤_៣៦ ម៉ោង ចំនួន ៥_៨ ដង ហើយត្រងយ
នោះទៅបាញ់ឬស្រោចបន្តិចៗលើរុក្ខជាតិដែលទទួលរ
បំផ្លាញ ។ ការបាញ់គួរតែធ្វើនៅពេលល្ងាច




ការពាររុក្ខជាតិវល្លិ និងកូនឈើឲ្យផុតពីការបំផ្លាញពីសត្វមាន់ ដោយគ្របស្លឹករុក្ខជាតិរាប៉ោ ឬដាក់សំបកឬស្រកីដូងដែលការពារ

ការពារកូនដំណាំបន្លែឲ្យផុតពីការបំផ្លាញរបស់ដង្កូវកាត់ស្លឹក ដោយដោតឈើរឹងជិតដើម

សំបកពងមាន់បែកៗដាក់ជុំវិញគ
កូនដំណាំ អាចការពារការបំផ្
ពីសត្វខ្យងបាន



ដាំល្ហុងខ្វៃនៅជុំវិញដំណាំសណ្តែក ដើម្បីអូសទាញពពួកដង្កូវកុំឲ្យចោមរោមស៊ីពពួកសណ្តែក



ខ្ទឹមបារាំង ខ្ទឹមស ពពួកជី ជីរ៉ាន់ស៊ុយ ជីនាងវង ។ល។
អាចការពារដំណាំម្ទេស ត្រប់ ប៉េងប៉ោះ ។ល។ ប្រសិនបើគេ
ដាំដំណាំទាំងនោះជាមួយគ្នា

រូបភាពទី ៤២ : គំនិតខ្លះៗសំរាប់ការពារក្តុកការពារដំណាំ

ជាវិធីសាស្ត្រមួយក្នុងការការពារទប់ទល់ជាមួយសត្វល្អិតដែលបំផ្លាញដំណាំ ។ ជួនកាលគេដាំដំណាំមួយចំនួនដើម្បីជួយអូសទាញសត្វល្អិតកុំឲ្យស៊ីដំណាំដែលគេយកផល ។

ការបង្កើតល័ក្ខខ័ណ្ឌសមស្របសំរាប់ពួកប៉ារ៉ាស៊ីត និងពពួករំពា (សត្វល្អិតដែលស៊ីសត្វល្អិតដទៃទៀត) ក៏ជាផ្នែកមួយនៃការការពារ និងកំចាត់សត្វល្អិតដែរ ។ ប្រសិនបើដំណាំខ្លះបង្ហាញចេញនូវការខូចខាតធ្ងន់ធ្ងរ យើងអាចប្រើថ្នាំសំលាប់សត្វល្អិតធ្វើពីស្លឹករុក្ខជាតិ ឬក៏សារធាតុគីមីងាយស្រួល ដូចជាល្បាយសាប៊ូ ប្រេងកាត ។ល។ ថ្នាំសំលាប់សត្វល្អិតដោយជាតិគីមីសំយោគ (ថ្នាំដែលលក់តាមផ្សារ) មិនត្រូវប្រើសំរាប់សួនដំណាំតាមគ្រួសារទេ ។ ជានិច្ចកាល យើងគួរចងចាំថា ប្រសិនបើយើងមានដីដែលមានជីវិត និងមានសុខភាពល្អ និងដាំដំណាំបានតាមរដូវត្រឹមត្រូវ ការបំផ្លាញដោយសត្វល្អិត ត្រូវបានកាត់បន្ថយយ៉ាងច្រើន ។

## ការពារដំណាំទប់ទល់នឹងជំងឺ

ជំងឺភាគច្រើនកើតចេញមកពីគ្រាប់ដំណាំ ឬមកពីដី ។ គ្រាប់ពូជត្រូវតែហាលឲ្យបានស្ងួត មុននឹងយកទៅទុក ហើយត្រូវទុកក្នុងកន្លែងស្ងួត ក្នុងកែវ ឬកំប៉ុងដែលគ្មានខ្យល់ចូល (មិនត្រូវដាក់ក្នុងថង់ប្លាស្ទិកទេ) ។ ត្រូវដកគ្រាប់ដែលខូច គ្រាប់មិនល្អចេញមុននឹងច្រកគ្រាប់ទុកពូជ ។ យើងត្រូវយល់ថា គ្រាប់ពូជប្រៀបដូចជាដំណាំដែលដេកលក់ មុននឹងយកវាទៅដាំគេត្រូវតែដាក់វាឲ្យត្រូវនឹងពន្លឺថ្ងៃ និងធ្វើឲ្យវាងើបឡើងវិញសិន ។

ក្នុងដីមានសារធាតុសរីរាង្គតូចៗដែលមានសារៈប្រយោជន៍ជាច្រើន ចំណែកឯពួកបំផ្លាញដល់ដំណាំមានតែតិចតួចប៉ុណ្ណោះ ។ តែនៅពេលដែលខ្វះខ្យល់ (អុកស៊ីសែន) នៅក្នុងដីដោយសារការដាំទឹក ឬដីហាប់ សមាមាត្រនៃចំនួនសរីរាង្គ មិនល្អនៅក្នុងដីនឹងកើតមានឡើងច្រើន ។ ដូចនេះ គេត្រូវធ្វើដីឲ្យធូរដោយដាំដំណាំ (ជាពិសេសដំណាំដែលមានឫសជ្រៅ) ឬតាមរយៈកាប់ប៉ុស ឬផ្ចាក់វា ។ យើងត្រូវការរកឲ្យឃើញនូវដំណាំដែលមានជំងឺឲ្យបានទាន់ពេល ហើយដកដំណាំទាំងនោះចោល ។ ជំងឺរបស់ដំណាំអាចឆ្លងពីមួយទៅមួយបានតាមរយៈសត្វល្អិត ឬដៃមនុស្សដែលប៉ះដំណាំទាំងនោះ ។

## ការពារដំណាំពីសត្វស្លាប និង សត្វពាហនៈ

មាន់ និងជ្រូកជាអ្នកបំផ្លាញសួនបន្លែច្រើនជាងគេ ដោយសត្វទាំងពីរនោះច្រើនត្រូវបានគេលែងចោល ហើយដើរកាយដី ឬអាចជ្រៀតចូលក្នុងសួនបានតាមចន្លោះតូចៗនៃរបង ។ ក្នុងករណីនេះ យើងដាច់ខាតត្រូវធ្វើរបងសួនឲ្យបានមាំល្អ របងរស់ (ដាំដើមឈើធ្វើរបង) និងការដាំដើមឈើ ឬរុក្ខជាតិជាជួរ ជារនាំងការពារល្អបំផុត ហើយមានរយៈពេលយូរផង ។ មែកឈើដែលមានបន្លា ស្លឹកត្នោត មែកឫស្សី ។ល។ គ្រាន់តែអាចជួយការពារបានតែមួយរយៈខ្លីប៉ុណ្ណោះ ។ ដំណាំខ្លះ ត្រូវការការការពារតែក្នុងដំណាក់កាលដែលវានៅកូនតូចៗប៉ុណ្ណោះ ។ ដើមឈើជាច្រើនត្រូវការការការពាររហូតដល់វាមានកំពស់ពី ១,៥ ទៅ ២ ម៉ែត្រ ។

ទុកសត្វពាហនៈក្នុងទ្រុងតូចៗ ដែលអាចប្តូរកន្លែងបាន គឺជាវិធីមួយល្អក្នុងការការពារដំណាំ និងបង្កើនគុណភាពដី ។ សត្វទីទុយ និងពស់ គឺជាមិត្តភក្តិកសិករ ព្រោះពួកវាជួយដេញកណ្តុរមិនឲ្យស៊ីដំណាំ ។



មុនដាំ គ្រាប់ពូជត្រូវត្រាំក្នុងទឹកក្ដៅឧណ្ហៗ (៥០-៦០°C) ក្នុងរយៈពេល ៣០-៥០ នាទី ដើម្បីសំលាប់ពពួកផ្សិត បន្ទាប់មកយកគ្រាប់ពូជនោះទៅត្រាំក្នុងជីកំប៉ុស្តទឹក ក្នុងរយៈពេល ៣-៤ ម៉ោង (មិនឲ្យត្រាំគ្រាប់ពូជដែលមានជាតិប្រេង ឬគ្រាប់នៃដំណាំបេកប្រេង) បន្តបកទៀតស្រង់គ្រាប់ពូជទាំងនោះចេញ ហើយយកវាទៅហាលក្នុងម្លប់ ក្នុងរយៈពេល ៥-៦ ម៉ោង រួចទើបយកទៅដាំ ។



នៅពេលដែលយើងដកកូនរុក្ខជាតិពីថ្នាលសាបយកទៅដាំ ត្រូវគ្របឫសរុក្ខជាតិទាំងនោះជាមួយនឹងក្រណាត់សើម ឬ ចំបើងសើម ។



កំណាត់មែកដែលដាំ ត្រូវកាត់ប្រវែង ២៥-៣០ ស.ម ហើយឲ្យមានកំរាស់ក្រាស់ជាងទាងដៃ



ប្រសិនបើកូនរុក្ខជាតិធំ ហើយឫសវាវែងខ្លាំង យើងត្រូវកាត់ឫសចេញខ្លះ ដោយប្រើសំភារះ (កន្ត្រៃ) កាត់យ៉ាងមុត

*រូបភាពទី ៤៣ : វិធានការផ្សេងៗដើម្បីធានាឲ្យកូនដំណាំ ឬពូជដំណាំដែលមានសុខភាពល្អ*



រុក្ខជាតិដែលមានស្លឹកដុះថ្មី ហើយចាប់ផ្តើមរួញ ឬផ្កាមានទំរង់ទ្រង់ទ្រាយខុសពីធម្មតា ត្រូវតែដកវាចោល

រុក្ខជាតិស្លឹកចាស់ ចាប់ផ្តើមរួញ អាចធ្វើឲ្យមិនទូផលបានច្រើន ប៉ុន្តែយើងអាចរក្សាទុក

រូបភាពទី ៤៤ : *ការគោះគោះដំណាំក្នុងដំណាក់កាលលូតលាស់*



ពពួកផ្ទី
(Amaranthaceae)
ផ្ទី



ពពួកដំណាំដែលស្ថិតនៅ
ក្នុងគ្រួសារ (Araceae)
ត្រាវ ដំឡូងដូង



ជ្រលង់ (Basellaceae)



ត្រកួន, ដំឡូងជ្វា
(Convolvulaceae)



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
(Compositae)
ផ្កាឈូករ័ត្ន សាឡាដ



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារស្ពៃ
(Cruceferae)
ខាត់ណា ស្ពៃក្តោប ស្ពៃចិន ខាត់ណាផ្កា
ឆៃថាវ ស្ពៃចង្កឹះ



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារត្រសក់
(Cucurbitaceae)
ត្រសក់ ម្រះ ឃ្លោក ត្រឡាច ល្ពៅ
ឪឡឹក ននោង

រូបភាពទី ៤៥ : ការបែងចែកដំណាំតាមគ្រួសារ



ពពួកដំណាំដែលស្ថិតនៅ
ក្នុងគ្រួសារ (Dioscoriaceae)
ដំឡូង (វល្លិ)
ឧទា.ដំឡូងពរោបចាន់
ដៃខ្លា



ពពួកដំណាំដែលស្ថិតនៅ
ក្នុងគ្រួសារ
(Enphorbiaceae)
ដំឡូងឈើ ល្ហុងខ្វែ



ពពួកជី (Labiatae)
ជីអង្កាម, ជីនាងវង



ពពួកដំណាំដែលស្ថិតនៅ
ក្នុងគ្រួសារគួរ
(Leguminoseae)
សណ្តែក
សណ្តែកគួរ សណ្តែកដាយ
សណ្តែកបារាំង ប៉ិគក់
សណ្តែកស្រូវ ពពាយផារ
ពពាយស្បែក
សណ្តែកអង្គុយ

រូបភាពទី ៤៥ : *ការបែងចែកដំណាំទៅតាមគ្រួសារ*



ខ្ទឹមបារាំង ខ្ទឹមស (Liliaceae)



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
(Malvaceae)
ម្ជូរព្រឹក្ស សរង្គ្រង ដៃនាង



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
Portulacaceae
ឧទា.ឃិនសិន



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
(Umbelliferae)
ការ៉ុត



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
(Solanaceae)
ប៉េងប៉ោះ ម្ទេស ត្រប់ ដំឡូងបារាំង



ពពួកដំណាំដែលស្ថិតនៅក្នុងគ្រួសារ
(Tiliaceae)
ក្រចៅបេកស្លឹក

រូបភាពទី ៤៥ : ការបែងចែកដំណាំទៅតាមគ្រួសារ

## ៨_ ការចិញ្ចឹមជីវិត និង ចំណីអាហាររបស់មនុស្ស

<u>គោលបំណង</u> :

*បន្ទាប់ពីអានជំពូកនេះចប់ អ្នកនឹងអាចយល់បានអំពី :*

- សារធាតុសំខាន់ៗដែលរាងកាយត្រូវការចាំបាច់ជារៀងរាល់ថ្ងៃ
- សារៈសំខាន់របស់ដំណាំបន្លែ និងឈើហូបផ្លែ ចំពោះសុខភាពរបស់មនុស្ស
- របៀបអនុវត្តក្នុងការដាំស្ល ឲ្យបានត្រឹមត្រូវ

ជាទូទៅយើងច្រើនមានជំនឿថាបន្លែ និងផ្លែឈើដែលថ្លៃ (ឧទាហរណ៍ ផ្លែប៉ោម ឬស្ពៃ) សុទ្ធតែមានខ្លាំងណាស់ ។ ផ្ទុយទៅវិញពពួកផ្លែឈើ និងបន្លែថ្លៃៗ មិនមែនសុទ្ធតែមានឱជារស និងសារធាតុចិញ្ចឹមច្រើននោះទេ ។ ការពិតផ្លែឈើតូចៗជាច្រើន ដូចជាកន្ទួត ក្រូចឆ្មារ ត្របែក ។ល។ មានផ្ទុកវីតាមីន និងសារធាតុរ៉ែជាច្រើន ។ ស្លឹករបស់ដើមឈើជាច្រើន (ដាំ ឬដុះឯង) ក៏សំបូរទៅដោយសារធាតុចិញ្ចឹមច្រើនដែរ ។ រុក្ខជាតិដែលដុះដោយឯកឯងជាច្រើនអាចមានសារធាតុចិញ្ចឹមច្រើនជាងបន្លែដែលដាំដោយមនុស្សទៀតផង ។

នៅពេលជ្រើសរើសដំណាំសំរាប់សួនក្នុងគ្រួសារ យើងត្រូវគិតជាពិសេសអំពីគុណភាព និងបរិមាណសារធាតុចិញ្ចឹម មិនមែនគិតពីតំលៃលក់ទីផ្សារទេ ព្រោះផលិតផលទាំងនោះភាគច្រើនគឺយើងផលិតសំរាប់ចំណីអាហារក្នុងគ្រួសារ ។ ទោះបីជាញ៉ាំបន្លែស្រស់ៗក្នុងបរិមាណតិចតួចក៏ដោយ ដូចជា ជី ផ្លែឈើ សណ្តែកដី វាអាចជួយពង្រឹងសមត្ថភាពរបស់ខ្លួនប្រាណយើងដើម្បីទប់ទល់នឹងជំងឺ និងការឆ្លងជំងឺបានដែរ ។ ដើម្បីរស់នៅបានយូរប្រកបដោយសុខភាពល្អ ខ្លួនប្រាណរបស់យើងត្រូវការចំណីអាហារគ្រប់គ្រាន់ ហើយចំណីអាហារនោះត្រូវតែមានបន្លែ និងផ្លែឈើច្រើនបែប ជាពិសេសសំរាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលបំបៅកូន និងកូនក្មេងតូចៗ ។

ដើម្បីឲ្យមានសុខភាពល្អ យើងត្រូវការឲ្យមានម្ហូបអាហារច្រើនបែប ។ ទន្ទឹមនឹងនេះ យើងត្រូវជ្រើសរើសយកវិធីសាស្ត្រចំអិនណាដែលមិនធ្វើឲ្យសារធាតុចិញ្ចឹមមានការបាត់បង់ច្រើន ។

បន្លែត្រូវលាងមុនពេលចិតសំបក ឬកាត់ មិនត្រូវលាងក្រោយពេលនោះទេ ។ បន្លែមើមក៏ត្រូវតែលាងឲ្យស្អាតមុននឹងចិតសំបក ឬកាត់ដែរ នៅពេលបកសំបកបន្លែត្រូវយកចេញតែផ្នែកខាងក្រៅប៉ុណ្ណោះ ដោយវីតាមីនភាគច្រើន និងសារធាតុរ៉ែមាននៅជាប់នឹងក្រោមសំបកតែម្តង ។ ដំណាំដូចជាមើមដំឡូងបី ត្រាវ ដំឡូងជ្វា ។ល។ ត្រូវស្ងោរ ឬអាំងសិន ទើបបកសំបកជាក្រោយ ។

បន្លែស្លឹក (ស្លឹកបន្លែ) ត្រូវឆាត្រឡប់ក្នុងរយៈពេលខ្លី ឬក៏ដាក់ក្នុងសម្លមួយភ្លែតនៅមុនពេលលើកឆ្នាំងសម្លចេញពីភ្លើង ។ ភាគច្រើននៃបន្លែស្លឹកអាចញ៉ាំឆៅបានបន្ទាប់ពីត្រាំក្នុងទឹកអំបិលរយៈពេល ១០_១៥ នាទី ។ សំរាប់កូនក្មេង យកល្អចំអិនបន្លែស្លឹកដោយចំហុយ ឬក៏ដាក់លាយក្នុងបបរ ។



ប្រភពនៃថាមពល : កាបូនអ៊ីដ្រាត
(ពពួកដំណាំដំឡូង និងធញ្ញជាតិ)



ប្រភពនៃវីតាមីនអា
(ពពួកដំណាំដែលមានស្លឹកបៃតង និងការ៉ុត)



បន្លែដែលសំបូរដោយវីតាមីនសេ

រូបភាពទី ៤៧ : ការបែងចែកដំណាំទៅតាមប្រភពសារធាតុចិញ្ចឹម



បន្លែដែលមានជាតិប្រូតេអ៊ីនច្រើន



ពពួកផ្លែឈើដែលសំបូរ
ដោយសារធាតុចិញ្ចឹម



បន្លែដែលមានជាតិកាល់ស្យូមច្រើន



បន្លែដែលមានជាតិដែកច្រើន

រូបភាពទី ៤៧ : ការបែងចែកចំណីអាហារតាមប្រភេទសារធាតុចិញ្ចឹម



ការយកសណ្តែកទៅបណ្តុះ
សំរាប់ធ្វើជាបន្លែ ជាវិធីមួយដ៏ល្អ



បន្លែត្រូវលាងទឹកឲ្យស្អាតមុននឹងយកទៅកាត់ ឬចិត



ការយកពពួកបន្លែមានស្លឹក
ពណ៌បៃតង និងពពួកសណ្តែក
ទៅចំហុយមុននឹងបរិភោគ
ជាវិធីមួយដ៏ល្អ



ការចំអិនដោយពន្លឺព្រះអាទិត្យ
អាចរក្សាសារធាតុមិនឲ្យបាត់បង់

រូបភាពទី ៤៨ : ឧទាហរណ៍ខ្លះៗអំពីការរៀបចំបន្លែ និងចំអិន

សណ្ដែកជាធម្មតាត្រូវញ៉ាំបន្ទាប់ពីចំហុយ ឬស្ងោរជាមុនសិន ។ បើញ៉ាំគ្រាប់សណ្ដែកស្ងួត យកល្អញ៉ាំសណ្ដែកបណ្ដុះ ឬក៏ស្ងោរវាបន្ទាប់ពីត្រាំទឹកបាន ១ យប់ក៏បានដែរ ។ គ្រាប់សណ្ដែកទុំ ភាគច្រើនមានសារជាតិពុល ឬក៏ពិបាកក្នុងការរំលាយអាហារ យកល្អគួរញ៉ាំសណ្ដែកពេលនៅខ្ចី ។

ការកំដៅម្ហូបដែលធ្វើឆ្អិនរួចហើយ មិនមែនជាទំលាប់ល្អទេ ។ គេគួរយកម្ហូបត្រជាក់ទៅកំដៅដោយដាក់ក្នុងចានក្រឡុក ដោយត្រាំក្នុងទឹកក្តៅ ឬទឹកឧណ្ហៗ ។ ម្ហូបដែលចំអិនរួច មិនត្រូវទុកនៅក្នុងឆ្នាំងធ្វើពីអាលុយ-មីញ៉ូមទេ ។ គេត្រូវផ្ទេរម្ហូបចំអិនរួចដាក់ទៅក្នុងចានសេរ៉ាមិច ឬចានកែវ ឬចានធ្វើអំពីឈើ ។

## ឧបសម្ព័ន្ធទី ១ : វិធីដ៏ល្អសំរាប់ថែរក្សាគ្រាប់ពូជក្នុងការដាំ

| រុក្ខជាតិ | ការរក្សាគ្រាប់ | រយៈពេលដែលគ្រាប់ពូជអាចដុះបាន | រយៈពេលដុះពន្លក | សេចក្តីត្រូវការគ្រាប់ពូជសំរាប់ដាំក្នុង ១ ម$^2$ |
|---|---|---|---|---|
| - ផ្ទី | ងាយស្រួល (SP) | ២ ឆ្នាំ | ខ្លី | ១_២ ក្រាម |
| - ត្រកួន | ងាយស្រួល (SP) | ២ ឆ្នាំ | ខ្លី | ៥_៦ _ |
| - ស្ពៃស្លឹក និងរ៉ាឌីស | ពិបាកណាស់ (XP) | ៤ ឆ្នាំ | ខ្លី | ២_៣ _ |
| - ផ្កាឈូករ័ត្ន | ងាយស្រួល (XP) | ២ ឆ្នាំ | ខ្លី | ២០_២៥ _ |
| - ល្ពៅ ឃ្លោក ត្រឡាច និង ត្រសក់ | ងាយស្រួល (XP) | ៣ ឆ្នាំ | ខ្លី_ល្មម | ៥_១០ _ |
| - សណ្តែក | ងាយស្រួល (SP) | ៣ ឆ្នាំ | ខ្លី | ៣០_៤០ _ |
| - ខ្ទឹមបារាំង | ពិបាក (XP) | ១_២ ឆ្នាំ | ខ្លី_ល្មម | ៣_៤ _ |
| - ពោតបារាំង(ដៃនាង) | ងាយស្រួល (SP) | ២ ឆ្នាំ | ល្មម_វែង | ៦_៨ _ |
| ម្ជូរព្រឹក្ស | ងាយស្រួល (SP) | ៣_៤ ឆ្នាំ | ខ្លី | ១_២ _ |
| - ប៉េងប៉ោះ | ងាយស្រួល (SP) | ២ ឆ្នាំ | វែង | ៦_៨ _ |
| - ម្ទេស និង ត្រប់<br>- ការ៉ុត | ពិបាក | ២_៣ ឆ្នាំ | វែង | ២_៣ _ |

<u>កំណត់សំគាល់</u>

ព្រលង់ ដំឡូងផ្លា ឃិនសិន ជាពួកដំណាំដែលបន្តពូជដោយកាត់ទង ។

- SP : ផ្កាមានលក្ខណៈដំណើរស្វ័យលំអង (ការបង្កាត់ជាមួយលំអងដែលមកពីដើមតែមួយ)
- XP : ផ្កាមានលក្ខណៈដំណើរលំអងកាត់ (តាមខ្យល់ ឃ្មុំ សត្វល្អិត)
- រយៈពេលដុះពន្លកខ្លីបំផុត ៣_៤ ថ្ងៃ ល្មម ៥_៦ ថ្ងៃ និង វែងបំផុត ៧_៨ ថ្ងៃ

ឧបសម្ព័ន្ធទី ២ : បន្លែមានប្រយោជន៍មួយចំនួន

* <u>ត្រសក់ និង (គុណសាររបស់វា)</u>

- មានសារធាតុចិញ្ចឹមទាប លើកលែងតែល្ពៅ និង ប្រះ ស្លឹករបស់វាសំបូរសារធាតុចិញ្ចឹម
- ដុះលូតលាស់ល្អនៅលើដីខ្សាច់ ត្រូវការកំដៅព្រះអាទិត្យពេញ (លើកលែងត្រសក់) ។ គ្រាប់ពូជរបស់វាងាយស្រួលក្នុងការថែរក្សាទុកដាក់
- មិនសូវធន់នឹងភាពរាំងស្ងួត ព្រមទាំងការលិចទឹក
- គ្រាប់របស់វាអាចលីងហូប និងគ្រាប់ភាគច្រើនមានជាតិប្រេងច្រើន

* <u>ប៉េងប៉ោះ និង (គុណសាររបស់វា)</u>

- លើកលែងតែគ្រប់ ។ ផ្លែ និងស្លឹកភាគច្រើនមានសារធាតុចិញ្ចឹមច្រើន
- លូតលាស់ល្អលើដីមានជីជាតិ ជាដំណាំដែលចូលចិត្តមានពន្លឺព្រះអាទិត្យ គ្រាប់ងាយស្រួលក្នុងការថែរក្សាទុកដាក់
- មិនធន់ទ្រាំនឹងការលិចទឹក ។ ប៉េងប៉ោះ និងម្ទេសអាចដុះលូតលាស់ក្នុងម្លប់បានខ្លះ
- មិនសូវធន់ទ្រាំនឹងជំងឺ ក្នុងអាកាសធាតុក្ដៅល្មម និងក្ដៅ

* <u>ដំឡូងជ្វា និង (គុណសាររបស់វា)</u>

- ស្លឹកដំឡូងជ្វា និងត្រកួន មានសារធាតុចិញ្ចឹមខ្ពស់ មើមរបស់វាក៏មានសារធាតុចិញ្ចឹមខ្ពស់ដែរ
- ដុះលូតលាស់លើដីគ្រប់ប្រភេទ ។ អាចដាំនៅក្នុងម្លប់ក៏បាន និងក្រោមពន្លឺថ្ងៃក៏បាន
- ងាយដុះលូតលាស់ នៅពេលយើងកាត់ទងវាដាំ
- ធន់ទ្រាំនឹងភាពរាំងស្ងួតបានល្មមចំពោះដំឡូងជ្វា និងធន់ទ្រាំនឹងភាពលិចទឹកបានល្មមចំពោះត្រកួន
- ធន់ទ្រាំនឹងជំងឺបានយ៉ាងខ្លាំង

* ផ្ទី

- ស្លឹកមានសារធាតុចិញ្ចឹមខ្ពស់
- ដុះលូតលាស់នៅលើដីស្ទើរតែគ្រប់ប្រភេទ ចូលចិត្តពន្លឺព្រះអាទិត្យ ។ គ្រាប់ពូជងាយស្រួលក្នុងការរក្សាទុកដាក់
- ធន់ទ្រាំនឹងភាពរាំងស្ងួតបានល្អ ហើយពូជខ្លះអាចដាំដុះក្នុងម្លប់បាន
- មានការបំផ្លាញពីសត្វល្អិតយ៉ាងច្រើន ជាពិសេសនៅរដូវភ្លៀង

* <u>ជ្រលង់</u>

- ស្លឹក និងដើមមានសារធាតុចិញ្ចឹមខ្ពស់
- ដុះលូតលាស់នៅលើដីស្ទើរតែគ្រប់ប្រភេទ ត្រូវការម្លប់ខ្លះៗ (ម្លប់ ៥០%) ។ ការពង្រីកពូជដោយដើម ឬគ្រាប់ ងាយស្រួលដុះលូតលាស់
- ធន់ទ្រាំនឹងដីដែលមានសំណើមច្រើន ប៉ុន្តែមិនធន់ទ្រាំនឹងភាពរាំងស្ងួតទេ
- កំរមានការបំផ្លាញពីសត្វល្អិត និងជំងឺណាស់

* <u>ផ្លែបួរព្រឹក្ស ឬសម្លុង</u>

- ស្លឹក និងផ្លែសំបូរដោយសារធាតុចិញ្ចឹមខ្ពស់
- ដុះលូតលាស់នៅលើដីគ្រប់ប្រភេទ ជាដំណាំចូលចិត្តពន្លឺព្រះអាទិត្យ ។ គ្រាប់ពូជងាយស្រួលក្នុងការរក្សាទុកដាក់
- ជាដំណាំធន់ទ្រាំនឹងភាពរាំងស្ងួត
- គ្រាប់របស់វាមានជាតិប្រេង អាចលីងបរិភោគបាន
- ដើមមានជាតិសរសៃដូចក្រចៅដែរ

* <u>ស្លឹកក្រចៅ</u> (ពពួកក្រចៅយកស្លឹកធ្វើជាបន្លែបាន)

- ស្លឹកប្រើជាអាហារ
- ដុះលូតលាស់នៅលើដីគ្រប់ប្រភេទ ត្រូវការម្លប់ខ្លះៗ (ម្លប់ ៥០%) ។ គ្រាប់ងាយស្រួលក្នុងការរក្សាទុក
- មានប្រភេទពូជមួយចំនួនធន់ទ្រាំនឹងការលិចទឹក
- ដើមរបស់វាមានសរសៃ សំរាប់ធ្វើជាខ្សែ

<u>ពពួកជាតិម្សៅ ឬអាមីដុង</u> : ពួកនេះជាអាហារចំបង ហើយជាប្រភពថាមពលដ៏សំខាន់ដល់រាងកាយ ។ នៅពេលដែលយើងធ្វើការ ខ្លួនប្រាណយើងបញ្ចេញថាមពលលឿនណាស់ ។ កូនក្មេងដែលកំពុងពេញលូតលាស់ត្រូវការចំណីអាហារដែលមានថាមពលច្រើន ដោយសារពួកគេស្ថិតក្នុងវ័យដែលកំពុងសកម្ម ។ ពពួកជាតិអាមីដុង ឬម្សៅ ភាគច្រើនត្រូវការ ស្ងោរ ឬអាំងសិន មុននឹងអាចញាំុបាន ។

<u>ប្រេង និងខ្លាញ់</u> : ប្រេងគឺជាធនធានថាមពល ហើយប្រេងក៏ជួយរក្សាឲ្យស្បែកយើងរលោង និងមានសុខភាពល្អផង ។ យើងបានប្រេងពីគ្រាប់ធញ្ញជាតិដែលមានជាតិប្រេង ដែលមាននៅក្នុងគ្រាប់ផ្កាឈូករ័ត្ន គ្រាប់សណ្តែកដី គ្រាប់សណ្តែក សៀង គ្រាប់ល្ង ។ ត្រី សាច់ ស៊ុត ទឹកដោះគោ ។ល។ គឺក៏មានសារជាតិប្រេងដែរ ។

<u>ប្រូតេអ៊ីន (ឬជាតិសាច់)</u> : ការលូតលាស់របស់សពាង្គកាយ ជាពិសេសសាច់ដុំដុះលូតលាស់អាស្រ័យទៅលើប្រូតេអ៊ីន ។ របបអាហារដែលគ្មានប្រូតេអ៊ីនគ្រប់គ្រាន់អាចបង្កឲ្យស្រកទំងន់ និងកាត់បន្ថយនូវសមត្ថភាពរបស់សរីរាង្គកាយ ក្នុងការប្រឆាំងទប់ទល់នឹងជំងឺ និងការឆ្លងនានា ។ ត្រី សាច់ ស៊ុត ។ល។ គឺជាប្រភពសំខាន់នៃប្រូតេអ៊ីន ។ ដូចគ្នាដែរ ពពួកសណ្តែកភាគច្រើន (ទាំងផ្លែខ្ចី និងគ្រាប់ទុំ) ក៏ជាប្រភពនៃប្រូតេអ៊ីនដែរ ។ អាហារដែលមានជាតិប្រូតេអ៊ីន ជាធម្មតា ក៏ត្រូវការចំអិនឲ្យបានល្អដែរមុននឹងញាំុ ។

<u>វីតាមីនអា</u> : មានសារៈប្រយោជន៍សំរាប់ធ្វើឲ្យភ្នែកភ្លឺ ឬមើលឃើញបានឆ្ងាយល្អ និងជួយការពារកុំឲ្យខ្វាក់មាន់ ។ ខ្លាញ់ត្រី ជាតិលឿងនៃស៊ុត គឺជាប្រភពសំខាន់នៃវីតាមីនអា ។ ស្លឹករបស់ពួកសណ្តែកមួយចំនួន ស្លឹកល្ពៅ និងស្លឹកម្រុំ ក៏មានវីតាមីននេះច្រើនដែរ ។

<u>វីតាមីនបេ</u> : ស៊ុតព៌ណលឿង និងសណ្តែក ជាពិសេសសណ្តែកបណ្តុះ មានផ្ទុកវីតាមីនបេដែលអាចជួយបង្កើនការរំលាយអាហាររបស់យើង ។ ការខ្វះវីតាមីនបេអាចបណ្តាលឲ្យមានជំងឺសើរស្បែក និងអាចបណ្តាលឲ្យរមាស់ជុំវិញបបូរមាត់និងមាត់ ។

<u>វីតាមីនសេ</u> : ជួយរក្សាធ្មេញ និងអញ្ចាញធ្មេញឲ្យមានសុខភាពល្អ ព្រមទាំងបង្កើនការរំលាយអាហារ និងបង្កើនសមត្ថភាពទប់ទល់ ឬភាពស៊ាំនឹងជំងឺផ្សេងៗ ។ កង្វះវីតាមីនសេក្នុងរបបចំណីអាហារ អាចបណ្តាលឲ្យធ្មេញពុក ឈាមអញ្ចាញធ្មេញ ផ្តាសសាយ និងក្អកជាញឹកញាប់ ។ ស្លឹកស្ពៃ និងបន្លែស្លឹកដទៃទៀត និងផ្លែឈើភាគច្រើន ជាពិសេសផ្លែឈើដែលមានជាតិជូរ ដូចជាក្រូចឆ្មារ កន្ទួត ត្របែក ។ល។ មានជាតិវីតាមីនសេច្រើន ។ ជាតិវីតាមីនសេនឹងត្រូវបាត់បង់ បើសិនជាចំអិនរយៈពេលយូរ ។

សារជាតិដែក ជាសារជាតិរ៉ែមួយដ៏សំខាន់នៅក្នុងចំណីអាហាររបស់យើង ។ វាជួយបង្កើតគ្រាប់ឈាមក្រហម ។ បើគ្មានជាតិដែកគ្រប់គ្រាន់នៅក្នុងខ្លួន អាចបណ្តាលឲ្យកើតជំងឺខ្វះឈាមក្រហម ដោយរាងកាយឡើងស្លេក ហើយ និងស្រកទំងន់ ។ល។ ស្ត្រីត្រូវការរបបអាហារដែលសំបូរដោយជាតិដែក ជាពិសេសនៅពេលដែលកើតផ្ទៃពោះ ឬបំបៅកូន ។ បន្លែស្លឹក ពួកសណ្តែកខ្ចីៗ ត្រយ៉ូងចេក និងដើមចេក ផ្លែឈើក្រៀម និងសណ្តែកដី ។ល។ គឺជាប្រភពសំខាន់នៃជាតិដែក ។

កាល់ស្យូម ជាសារជាតិរ៉ែសំខាន់មួយទៀតដែលយើងត្រូវការឲ្យមានទៀងទាត់សំរាប់ជួយឲ្យឆ្អឹង និងធ្មេញរបស់យើងរឹងមាំ ។ ត្រីតូចៗ ក្តាម បង្គារ ។ល។ គឺជាប្រភពនៃជាតិកាល់ស្យូមដ៏សំខាន់ ។ បន្លែស្លឹកជាច្រើន ក៏មានជាតិកាល់ស្យូមច្រើនដែរ ពពួកដំណាំមើម ឬពពួកដំឡូង ក៏មានសារជាតិកាល់ស្យូម និងជាតិម៉ាញ៉េស្យូម ព្រមទាំងសារជាតិរ៉ែដទៃទៀត ដែលសរីរាង្គយើងត្រូវការទៀងទាត់ តែក្នុងបរិមាណតិច ។ បើយើងញុំាបន្លែ ផ្លែឈើ និងសណ្តែកដី គ្រាប់ធញ្ញជាតិដែលមានជាតិប្រេង និងពពួកមើមឲ្យបានទៀងទាត់ក្នុងបរិមាណតិច វាអាចជួយធ្វើឲ្យសារពាង្គកាយយើងឲ្យនៅរឹងមាំ និងមានសុខភាពល្អ ៕

# ពាក្យគន្លឹះ

**កញ្ចាចង្រៃ** គឺជាសត្រូវរបស់ដំណាំដែលបង្កនូវមហន្តរាយដល់ដំណាំ ។ កញ្ចាចង្រៃទាំងនោះមាន : សត្វល្អិតចង្រៃ, រុក្ខជាតិចង្រៃ (ស្មៅ), ជំងឺ ។

**កសិរុក្ខកម្ម** ការធ្វើកសិកម្មដោយមានផ្តុំដើមឈើបញ្ចូលជាមួយ

**កសិកម្ម_កសិករ** ការដាំដំណាំ និងចិញ្ចឹមសត្វ អ្នកធ្វើកសិកម្ម

**ការគ្របដី** គឺជារុក្ខជាតិ ឬសារធាតុដែលមានជីវិត (ឧទា.ចំបើង, ស្លឹកឈើងាប់ៗ) ដែលគេដាំ ឬប្រើ សំរាប់គ្របដី ក្នុងគោលបំណងការពារដីកុំឲ្យមានការហូរសឹកដោយទឹកភ្លៀង ឬកុំឲ្យ បាត់បង់សំណើមក្នុងដី និងធ្វើឲ្យដីមានជីជាតិផង ។

**ការចំហដី** គឺការទុកដីឲ្យនៅចោលទំនេរ ដោយគ្មានការដាំរុក្ខជាតិគ្របពីលើ ឬគ្មានគ្របដោយសារធាតុគ្មានជីវិតផ្សេងៗ ដីប្រភេទនេះ ងាយមានការបាត់បង់ដោយការហូរច្រោះតាមទឹកភ្លៀង ឬធ្វើឲ្យបាត់បង់សំណើមក្នុងដី និងធ្វើឲ្យដីគ្មានជីជាតិ ។

**កាល់ស្យូម** សារធាតុពណ៌សដូចប្រាក់មាននិមិត្តសញ្ញាគីមី Ca ដូចជាថ្មកំបោរ ជាវត្ថុធាតុដើមយ៉ាងសំខាន់សំរាប់ផលិតជីគីមី

**ជីកំប៉ុស្តគោក** គឺជីដែលបានមកពីការទុកសារធាតុសរីរាង្គឲ្យពុក ឬបំបែកធាតុក្នុងរយៈពេលប្រហែល ៣ ខែ ។ ការបំបែកធាតុនេះ កើតមានឡើងដោយសារវត្តមានរបស់សត្វល្អិតផ្សេងៗ ខ្យល់ សំណើម និង កំដៅ

**ជីកំប៉ុស្តរាវ** ជាជីលាមកសត្វរាវ (មាន់, ទា, ពពែ, ទន្សាយ ។ល។) ដែលប្រើសំរាប់ច្បារដំណាំតាមគ្រួសារ

**ដីបាស** គឺជាប្រភេទដីដែលមានជាតិប្រៃ ដីប្រភេទនេះរុក្ខជាតិភាគច្រើនមិនសូវដុះលូតលាស់ល្អទេ (ជួនកាលគេហៅថាដីជាតិអាល់កាឡាំង)

**ដីអាស៊ីត** គឺជាប្រភេទដីដែលមានជាតិជូរ ។ ដំណាំភាគច្រើនមិនសូវដុះលូតលាស់ល្អលើដីប្រភេទនេះទេ

**ដីល្អ** គឺជាដីដែលមានជីជាតិ មានមីក្រូសរីរាង្គរស់នៅច្រើន ដីនេះអាចដាំដំណាំដុះលូតលាស់ ល្អ និងទទួលបានទិន្នផលខ្ពស់

**ដំណាំគ្របដី** — គឺដំណាំទាំងឡាយណាដែលគេដាំដើម្បីជាគំរបដល់ដី (សូមមើលគំរបដី)

**ដំណាំចំរុះ** — គឺជាដំណាំ ២ ឬច្រើនមុខដាំលាយគ្នា នៅលើផ្ទៃដីតែមួយ

**ដំណាំឆ្លាស់** — គឺជាការដាំផ្លាស់ប្តូរមុខដំណាំ ពីរដូវមួយទៅរដូវមួយទៀតបន្តបន្ទាប់គ្នាលើផ្ទៃដីដដែល ។ ឧទាហរណ៍ : រដូវទី ១ ដាំពោត, រដូវទី ២ ដាំស្រូវលើដីដដែល និងរដូវទី ៣ ដាំសណ្តែក ។ល។ ជួនកាលគេហៅថាការដាំបង្វិល

**ដំណាំគូកន** — ជាដំណាំដែលអាចដាំផ្សំជាមួយគ្នាបាន ដោយគ្មានបញ្ហា
ឧទាហរណ៍ : ប៉េងប៉ោះ ម្ទេស ត្រប់ អាចដាំជាមួយខ្ទឹមបារាំង ការ៉ុត សណ្តែកគ្រប់ប្រភេទបាន តែបើដាំបានជាមួយពពួកដំណាំស្ពៃមិនសូវលូតលាស់ល្អទេ ។

**ដំណាំមានផ្ទុកសារធាតុបណ្តេញសត្វ** — គឺជាដំណាំ ឬរុក្ខជាតិដែលមានជាតិពុល ឬមានក្លិនអាក្រក់ម្យ៉ាង (ក្រពុល ឬក្អួល) ដែលធ្វើឲ្យសត្វល្អិតមិនចូលចិត្តទៅក្បែរ (ឧទាហរណ៍ : ថ្នាំជក់, ខ្ទឹមបារាំង, ខ្ទឹមស, ម្រះព្រៅ, ពពួកជី ផ្កាស្បៃរឿង) ។

**ដំណាំយូរអង្វែង** — គឺជាដំណាំដែលមានអាយុកាលដុះលូតលាស់ច្រើនឆ្នាំ

**ដំណាំមានសុខភាពល្អ** — គឺជាដំណាំដែលដុះលូតលាស់ល្អ គ្មានការបំផ្លាញពីជំងឺ និងសត្វល្អិតចង្រៃ មានដើមរឹងមាំល្អ

**ដំណាំតាមរដូវ** — ដំណាំទាំងឡាយដែលគេដាំទៅតាមរដូវរបស់វា ?

**ណេម៉ាតូត** — ពពួកសត្វល្អិតតូចៗដែលមានរាងដូចជន្លេន ។ សត្វល្អិតនេះរស់នៅក្នុងដី ហើយពពួកប្រភេទខ្លះអាចបំផ្លាញឫសដំណាំ ។

**ទំរង់របស់ដី** — របៀប ឬរបាង្គនៃការផ្គុំចូលគ្នារបស់ផ្នែកតូចៗនៃដី ។
ឧទាហរណ៍ នៅពេលយើងភ្ជួរ ឬកាប់ដី យើងអាចឃើញថាដីខ្លះមានទំរង់រាងជាពហុកោណ ឬជាសន្លឹកៗ ។ល។

**ទីក្រាត** — ពពួកសារធាតុដែលមានជាតិអាសូត ហើយអាចប្រើដើម្បីជួយឲ្យដីមានជីជាតិ ។

**បរិមាណសារធាតុសរីរាង្គរបស់ដី** — កាកសំណល់របស់រុក្ខជាតិ និងសត្វដែលមាននៅក្នុងដី

| | |
|---|---|
| បទពិសោធន៍ | ចំណេះដឹង ឬជំនាញដែលទទួលបានមកពីការសាកល្បង ឬការអនុវត្តន៍ផ្ទាល់ ឬឃើញផ្ទាល់ |
| បរិស្ថាន | បរិដ្ឋាននៃជុំវិញខ្លួនទាំងអស់ ឬសំណុំល័ក្ខខ័ណ្ឌក្រៅទាំងអស់ដែលមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់ឯកតៈ ឬបណ្តុលភាវៈ |
| បាក់តេរី | ពពួកសត្វល្អិតតូចៗដែលជួយធ្វើឲ្យសារធាតុសរីរាង្គពុក ឬរលួយ |
| ប៉ារ៉ាស៊ីត (ប៉ារ៉ាស៊ីត) | ពពួករុក្ខជាតិ ឬសត្វ ដែលរស់នៅដោយសារគេ |
| ប្រូតេអ៊ីន | ជាជីវជាតិអាហារដែលមានជាតិសាច់ មាននៅក្នុងពពួកបន្លែ, ដំណាំធញ្ញជាតិ, ត្រី, សាច់, ស៊ុត ។ល។ បន្លែដែលសំបូរជីវជាតិប្រូតេអ៊ីនច្រើនជាងគេ គឺពពួកសណ្តែក ជាពិសេសគឺពពួកសៀង ។ |
| បំរែបំរួល | ការប្រែប្រួល |
| បុគ្គលិកលក្ខណៈ | ជាលក្ខណៈរបស់បុគ្គលម្នាក់ៗ ឬមនុស្សម្នាក់ៗ |
| ពពួកពោ | ពពួកសត្វដែលចិញ្ចឹមជីវិតដោយសត្វដទៃជាអាហារ (ពស់ ទីទុយ កង្កែប) |
| ពហុប្រយោជន៍ | ដែលមានប្រយោជន៍ច្រើន ដែលអាចប្រើបានច្រើនមុខ ។ |
| ពិសោធន៍ | ការល្បងមើល ឬសាកមើលឲ្យឃើញការពិត ។ |
| មមោក | ជាសារធាតុសរីរាង្គនៅក្នុងដីដែលពុក ឬបំបែកធាតុបានល្អរួចរាល់ មមោកធ្វើឲ្យដីមានពណ៌ក្រមៅ ហើយជួយធ្វើឲ្យកំទេចដីស្អិតជាប់គ្នា ។ |
| មីក្រូសរីរាង្គ ឬមីក្រូសារពាង្គកាយ | ជាពពួកសត្វល្អិតដែលមិនអាចមើលឃើញតាមរយៈភ្នែក ។ ដើម្បីមើលពពួកសត្វនេះឃើញ គេត្រូវការកែវពង្រីក ឬមីក្រូទស្សន៍ ។ |
| របងរស់ | ជារុក្ខជាតិដែលគេដាំធ្វើជារបង |
| រ៉ាឌីស | ដំណាំដែលមើមមូលតូចៗ មានរសជាតិដូចឆៃថាវ |
| លិបិក្រម | លំដាប់ ឬការរៀបពាក្យសំខាន់តាមលេខរៀង (ព្យញ្ជនៈ) |

| | |
|---|---|
| វដ្ត | ការវិលទៅមក ឬដំណើរការវិលទៅមកទៅតាមលំដាប់ដដែលៗ |
| វាយនភាពរបស់ដី | សំដៅលើភាគរយរបស់ផ្នែកខ្សាច់ ល្បាប់ និង ផ្នែកល្បាយរបស់ដី |
| វិនិច្ឆ័យ | ការពិចារណាដោយល្អិត ការពិនិត្យមើលឲ្យឃើញពិត ការជំនុំជំរះក្តី |
| វីតាមីន | គឺជាពួកជីវជាតិដែលជួយទ្រទ្រង់សារពាង្គកាយ ដូចជាវីតាមីនអា មាននៅក្នុងបន្លែស្លឹក |
| សរីរាង្គ | អ្វីដែលកើតឡើង ឬបានមកពីរបស់មានជីវិត (រុក្ខជាតិ និង សត្វ) |
| សារធាតុចិញ្ចឹម | ១) សារធាតុដែលយើងត្រូវការចាំបាច់សំរាប់ការលូតលាស់ សំរាប់ជាប្រភពថាមពល និងជួយថែរក្សារាងកាយឲ្យមានសុខភាពល្អ ។<br>២) សារធាតុដែលរុក្ខជាតិត្រូវការចាំបាច់ដើម្បីលូតលាស់ និងផលិតផ្លែផ្កា ។ សារធាតុដែលរុក្ខជាតិត្រូវការចាំបាច់ មានដូចជា កាបូន អ៊ីដ្រូសែន អុកស៊ីសែន អាសូត ហ្វូស្វ័រ ប៉ូតាស្យូម ម៉ាញ៉េស្យូម ស៊ុលហ្វួរ ។ល។ |
| សារធាតុសរីរាង្គ | រូបធាតុទាំងឡាយណាដែលបានមកពីរុក្ខជាតិ ឬសត្វ |
| សារធាតុរ៉ែ | សារធាតុអសរីរាង្គ (គ្មានជីវិត) ដែលមាននៅក្នុងធម្មជាតិ |
| សូលុយស្យុង | ល្បាយដែលកើតឡើងពីការរលាយធាតុមួយចូលជាមួយធាតុមួយទៀត<br>ឧទា. ស្ករលាយជាមួយទឹក ចេញជាសូលុយស្យុងស្ករ |
| សួនរង្វង់ | ជាប្រភេទសួនបន្លែតាមគ្រួសារម្យ៉ាង ដែលមានរាងដូចរណ្តៅបាតខ្ទះ ហើយមានដាំដំណាំរាងជារង្វង់ព័ទ្ធជុំវិញ ។ |
| សមាសភាគ | ផ្នែកផ្សេងៗដែលមានក្នុងអ្វីមួយ |
| សីតុណ្ហភាព | ភាពនៃបរិយាកាសត្រជាក់និងក្តៅដែលផ្សព្វផ្សាយមកប៉ះលើខ្លួនយើង |
| សមាមាត្រ | ភាពស្មើគ្នា |
| សំណើម | ភាពសើម |
| សេវាកម្ម | ការធ្វើអ្វីមួយដើម្បីបំរើ ឬផ្តល់ផ្គង់ឲ្យអ្នកដទៃ |
| សេរ៉ាមិច | វត្ថុផ្សំឡើងពីដីឥដ្ឋដែលដុតក្នុងកំដៅខ្ពស់ |

| | |
|---|---|
| អាទិភាព | ភាពខ្លាំង អ្វីដែលសំខាន់ជាងគេ ឬត្រូវធ្វើមុនគេ |
| អាលុយមីញ៉ូម | លោហៈស្រាលពណ៌ស មានផ្ទៃកលោហៈនិងមាននិមិត្តសញ្ញា Al |
| អុកស៊ីសែន | ឧស្ម័នគ្មានក្លិន គ្មានពណ៌ គ្មានរសជាតិ មិនពុល ជាធាតុបង្កយ៉ាងសំខាន់សំរាប់មនុស្ស សត្វ និងរុក្ខជាតិ (ខ្យល់សំរាប់ដកដង្ហើម) |
| អាល់កាឡាំង | ពពួកសារធាតុដែលមានជាតិប្រៃ ដូចជាក្បុង |
| ឧបសម្ព័ន្ធ | ចំណែកដែលគេបន្ថែមនៅផ្នែកខាងក្រោយ ឬផ្នែកបញ្ចប់របស់សៀវភៅ |
| អេកូឡូស៊ី | វិទ្យាសាស្ត្រដែលសិក្សាអន្តរអំពើ ទំនាក់ទំនងរវាងអ្វីៗឬផ្នែកដែលមានជីវិត ជាមួយអ្វីៗ ឬផ្នែកដែលមិនមានជីវិត |

# លិបិក្រម


- កក្តា (១០)
- កក្តាចង្រៃ (១០)
- កំប៉ុស្តគោក (១៦)
- កំប៉ុស្តទឹក (១៦)
- កសិរុក្ខកម្ម (១១)
- ការចំហដី (១៣)
- ការគ្របដី (១៦)
- គន្លឹះ (៣៦)
- គុណភាពល (៣)
- ដីជាតិបាស (៣៦)
- ដីដែលមានជីវិត (៥១)
- ដីដែលមានសុខភាពល្អ (៤៦)
- ដីល្អ (៨)
- ដីជាតិអាស៊ីត (៣៦)
- ដំណាំដែលមានសុខភាពល្អ (៥១)
- ដំណាំតាមរដូវ (៣)
- ដំណាំឆ្លាស់ (១៦)
- ដំណាំចំរុះ (៤៦)
- ដំណាំយូរអង្វែង (៣)
- ដំណាំច្រើនជាន់ (២៧)
- ដំណាំគូកន (៥១)
- ដំណាំមានផ្ទុកសារធាតុបណ្តេញសត្វ (៤៦)
- ថាមពល (៦៦)
- ណេកម៉ាតូត (១៥)
- ទំរង់ (៨)
- ទីក្រាត (១៥)
- បាក់តេរី (១៥)
- ប្រតិទិន (៥១)

- ប្រូតេអ៊ីន (៦៦)
- ប៉ាស្ទ័រល្អ (៦៧)
- មីក្រូសរីរាង្គ (២៧)
- របររស់ (៣)
- មី (៤)
- លក្ខខណ្ឌ (១)
- សម្ភារ (៤)
- សមាសភាព (៨)
- វិធីធ្វើ (៣៦)
- វិធីសាស្ត្រ (៣)
- សុខភាព (៨)
- សមត្ថភាពស្រូបទឹករបស់ដី (២៥)
- សមាសធាតុ (១០)
- ស្ថិរភាព (១)
- សារធាតុដី (៨)
- សារធាតុសរីរាង្គ (៨)
- សារធាតុចិញ្ចឹម (១)
- សារពាង្គកាយ (៦៦)
- សីតុណ្ហភាព (២៥)
- ស្លឹកឈើ (១៦)
- អេរ៉ូប៊ិច (៦២)
- អេរ៉ាកបូ (១)
- អតិសុខុមប្រាណ (៩)
- អ្នកផ្សព្វផ្សាយ (១)
- ឥទ្ធិពល (២៥)















នារីអន្តរជាតិដើម្បីអភិវឌ្ឍន៍ ឬ អាយដា (IWDA) គឺជាអង្គការអូស្ត្រាលី ធ្វើការជាមួយនារី និងដើម្បីជួយនារី ។ នៅប្រទេសកម្ពុជា អង្គការអាយដា មានកម្មវិធីអភិវឌ្ឍន៍ជួយដល់ស្ត្រីក្រីក្រនៅខេត្តសៀមរាប និងបាត់ដំបង តាមរយៈគំរោងអភិវឌ្ឍន៍ផ្សេងៗ ដូចជា ធនាគារសត្វ សួនដំណាំចំរុះ ជាលក្ខណៈគ្រួសារ កម្មវិធីផ្គត់ផ្គង់ទឹក ឥណទាន ស្រែប្រាំង និង ការបំបាត់អំពើហិង្សាតាមគ្រួសារ ។ ការជំរុញសួនដំណាំចំរុះ ជាលក្ខណៈគ្រួសារ តាមរយៈអ្នកផ្សព្វផ្សាយជាកសិករ ជាកម្មវិធីមួយ ក្នុងចំណោមកម្មវិធីសំខាន់ៗ ដែលត្រូវពង្រីក នាពេលបច្ចុប្បន្ន ។








**International Women's Development Agency**

អាសយដ្ឋានទំនាក់ទំនង នៅភ្នំពេញ : ផ្ទះលេខ ១៧ ផ្លូវលេខ ២៩៤

ទូរស័ព្ទ និង ទូរសារលេខ : ០២៣ ២១៦ ៩២២